PTI0060

សម្ភាសន៍ជាមួយឈ្មោះ ព្រំ ណៃ ភេទស្រី អាយុ៥៧ឆ្នាំ

រស់នៅភូមិស៊ឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់

មុខងារសម័យខ្មែរក្រហមៈ ពេទ្យស្រុក

មុខងារបច្ចុប្បន្នៈ ធ្វើចំការ

សម្ភាសន៍ដោយៈ ឡុង ដានី

សម្ភាសន៍ថ្ងៃទី២០ ខែ ឧសភា ឆ្នាំ២០១១

សរុបទំព័រៈ ២៦

០០:៥៦:៥៤

ដានីៈ មីងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង តើមីងឈ្មោះអីដែរ?

ណៃៈ ឈ្មោះ ព្រំ ណៃ ។

ដានីៈ អាយុប៉ុន្មានមីង?

ណៃៈ អាយុ៥១ឆ្នាំ ។

ដានីៈ មីងសព្វថ្ងៃរស់នៅភូមិអី?

ណៃៈ រស់នៅភូមិស៊ឹងថ្មី ។

ដានីៈ ឃុំអី?

ណៃៈ ឃុំប្រម៉ោយ ។

ដានីៈ ស្រុកវាលវែង?

ណៃៈ ចា៎! ខេត្តពោធិ៍សាត់ ។

ដានីៈ ពូប្ដីរបស់មីងគាត់ឈ្មោះអីដែរ?

ណៃៈ ឈ្មោះ ឡេង ភាព ។

ដានីៈ គាត់អាយុប៉ុន្មានហើយ?

ណៃៈ អាយុ៧៥ ។

ដានីៈ ហើយមីងមានកូនចៅទាំងអស់?

ណៃៈ មាន៧នាក់ ។

ដានីៈ ស្រីប៉ុន្មាន ហើយប្រុសប៉ុន្មាន?

ណៃៈ ស្រី៣នាក់ហើយប្រុស៥នាក់ ។

ដានីៈ មីងប្រកបមុខរបររកស៊ីធ្វើអី?

ណៃ៖	ធ្វើចំការ ។

ដានី៖	ហើយមានធ្វើអីទៀតទេ?

ណៃ៖	អត់មានធ្វើអីផង ។

ដានី៖	មីងស្រុកកំណើតកើតជានៅភូមិឃុំស្រុកអីដែរ?

ណៃ៖	នៅស្រុកស្រែអំបិល នៅភូមិជ្រាំង ឃុំដងតែង ខេត្តកោះកុង ។

ដានី៖	ឪពុកមីងគាត់ឈ្មោះអីទៅ?

ណៃ៖	គាត់ឈ្មោះ វីរ សៀង ។

ដានី៖	សព្វថ្ងៃគាត់នៅរស់ទេ?

ណៃ៖	គាត់ស្លាប់ហើយ ។

ដានី៖	ស្លាប់តាំងពីពេលណា?

ណៃ៖	ស្លាប់តាំងពី៧៧ គេយកទៅវ៉ៃចោល គាត់អ្នកចេះដឹងម្នាក់ គាត់ដូចបារាំងអញ្ចឹង គាត់ចេះដឹងហើយគេយកទៅវ៉ៃចោល ។

ដានី៖	ចុះម្ដាយមីង?

ណៃ៖	ម្ដាយខ្ញុំស្លាប់បាត់ហើយ ។

ដានី៖	គាត់ឈ្មោះអីដែរ?

ណៃ៖	ម្ដាយខ្ញុំឈ្មោះ ព្រំ ឈាក ។

ដានី៖	គាត់ស្លាប់តាំងពីអន្កាល់?

ណៃ៖	គាត់ស្លាប់កាលឆ្នាំ៩៦ ពេលដែលខ្ញុំរើមកនៅនេះ ។

ដានី៖	អញ្ចឹងមីងយកត្រកូលតាមម្ដាយ?

ណៃ៖	ចា៎! ធ្លាប់ដាក់អញ្ចឹងក៏ដាក់មករហូតមក ។

ដានី៖	ហើយមីងមានបងប្អូនបង្កើតប៉ុន្មាននាក់?

ណៃ៖	ខ្ញុំមានបងប្អូនបង្កើត៨នាក់ ។

ដានី៖	ស្រីប៉ុន្មាន ហើយប្រុសប៉ុន្មាននាក់?

ណៃ៖	ប្រុស៣នាក់ហើយប្រុស៥នាក់ ។

ដានី៖	ចុះមីងកូនទីប៉ុន្មាន?

ណៃ៖	ខ្ញុំកូនទី១ ។

ដានី៖	ចុះមីងកាលពីមុនបានរៀនសូត្រដល់ណាដែរ កាលពីក្មេងៗ?

ណៃ៖ ខ្ញុំអត់មានបានរៀនសូត្រទេ ។

ដានី៖ អត់មានបានរៀនទេ?

ណៃ៖ អត់មានបានរៀនផង ។

ដានី៖ ហើយមីងចេះអាន ចេះសរសេរដែរអត់?

ណៃ៖ ចេះអានតិចៗ បើសរសេរអត់ចេះទេ ចេះមើលតិចតួច ។

ដានី៖ មីងចេះអានចេះសរសេរតិចតួច?

ណៃ៖ ចាំ!

ដានី៖ ចុះមីងពេលរដ្ឋប្រហារឆ្នាំ៧០ហើយ មីងនៅណាទៅ?

ណៃ៖ ឆ្នាំ៧០?

ដានី៖ បាទ! ពេលរដ្ឋប្រហារលន់ នល់?

ណៃ៖ ពេលរដ្ឋប្រហារ លន់ នល់ ហ្នឹងនៅក្នុងភូមិហ្នឹងហើយធ្វើស្រែធ្វើចំការហ្នឹង ដល់ពេលឆ្នាំ៧៣បានខ្ញុំចេញធ្វើបដិវត្តន៍ ។

ដានី៖ នៅក្នុងភូមិធ្វើស្រែ?

ណៃ៖ ចាំ! ធ្វើស្រែចំការ ។

ដានី៖ ឆ្នាំ៧៣មីងធ្វើបដិវត្តន៍?

ណៃ៖ ធ្វើបដិវត្តន៍ធ្វើពេទ្យ ។

ដានី៖ កាលហ្នឹងយើងធ្វើបដិវត្តន៍ហ្នឹងគេជ្រើសរើសឲ្យធ្វើឬក៏មីងស្ម័គ្រចិត្ត?

ណៃ៖ យើងស្ម័គ្រចិត្តទៅធ្វើពេទ្យ ។

ដានី៖ ធ្វើពេទ្យនៅណា?

ណៃ៖ ពេទ្យឃុំ ។

ដានី៖ នៅឃុំដងពែងហ្នឹង?

ណៃ៖ ចាំ!

ដានី៖ ធ្វើពេទ្យឃុំហ្នឹងបានរយៈពេលប៉ុន្មាន?

ណៃ៖ ធ្វើពេទ្យឃុំហ្នឹងបានយូ ។

ដានី៖ កាលហ្នឹងមីងនៅក្មេងទេ?

ណៃ៖ នៅក្មេង ។

ដានី៖ អាយុប៉ុន្មានកាលហ្នឹង?

ណៃ៖ កាលចូលធ្វើបដិវត្តន៍ហ្នឹងអាយុ៧៦ ខ្ញុំអាយុ១៦ដដែល ។

ដានី:		៧៦អាយុ១៦ អញ្ចឹងកាលហ្នឹងទើបតែអាយុ១២-១៣ឆ្នាំទេ?

ណៃ:		ចា៎!

ដានី:		មីងចូលធ្វើបដិវត្តន៍ធ្វើពេទ្យហ្នឹងតាំងពីឆ្នាំ៧៣?

ណៃ:		ចា៎! កាលឆ្នាំ៧៣ហ្នឹងខ្ញុំអាយុ១២ឆ្នាំ ។

ដានី:		១២ហ្នឹងនៅក្មេងមែនទែន?

ណៃ:		ចា៎! កាលចូលធ្វើបដិវត្តន៍មុនដំបូងហ្នឹងវាក្រពេក ហើយខ្ញុំស័គ្រចិត្តចូលធ្វើបដិវត្តន៍ហ្នឹងនៅក្មេងៗណាស់ ហើយមានប្អូនៗក្មេងៗដាងហ្នឹងទៀតចូលធ្វើ ។

ដានី:		គ្នាច្រើនទេពេលដែលចូលធ្វើបដិវត្តន៍ហ្នឹង?

ណៃ:		ធ្វើមុនដំបូងហ្នឹងអត់សូវមានទេ ដល់ពេលហើយបានខ្ញុំមកចាប់ផ្តើមធ្វើនៅពេទ្យស្រុក ។

ដានី:		ឆ្នាំណាមកនៅពេទ្យស្រុក?

ណៃ:		ឆ្នាំ៧៤ ។

ដានី:		៧៤ហ្នឹងមកពេទ្យស្រុកណា?

ណៃ:		មកពេទ្យស្រុកស្រែអំបិលហ្នឹង ។

ដានី:		កាលហ្នឹងគេផ្លាស់មកពេទ្យស្រុកស្រែអំបិល?

ណៃ:		ចា៎!

ដានី:		ធ្វើអីខ្លះនៅពេទ្យ?

ណៃ:		ព្យាបាលអ្នកជម្ងឺអ្នករបួសហ្នឹង ពីឆ្នាំ៧៣ហ្នឹងយើងមិនទាន់វៃគ្នាខ្លាំងទេ ដល់ពេលឆ្នាំ៧៤បានវៃគ្នារបួស របួសហើយព្យាបាលទាំងយប់ទាំងថ្ងៃ ពេទ្យ១០នាក់ អ្នកជំងឺ១ពាន់នាក់ ។

ដានី:		ពេទ្យគ្នា១០នាក់ អ្នកជំងឺ១ពាន់នាក់?

ណៃ:		ចា៎!១ពាន់នាក់គ្រុនចាញ់នៅខេត្តកំពង់សិលាយើងហ្នឹងហ្នង យ៉ាប់ណាស់អត់មានបានដេកទេទាំងយប់ទាំងថ្ងៃអញ្ចឹងយើងចេះនាំគ្នាស្មគ្រ័ចិត្តធ្វើទៅ អត់មានពេទ្យចេះតែខំតស៊ូហ្នង ប៉ុនអត់មានខ្វះអីហូបទេទាំងយប់ទាំងថ្ងៃហ្នង ។

ដានី:		បាទ!អញ្ចឹងយើងអ្នកស្រែអំបិលព្យាបាលអ្នកជំងឺ ព្យាបាលអ្នករបួស?

ណៃ:		ហើយនឹងអ្នកគ្រុនចាញ់ហ្នឹងគឺចេញ២០ចូល១០ ចេញ១០ចូល២០ហ្នង ឆ្នាំ៧៤ហ្នឹងគឺខ្លាំងហើយដល់ពេលយន្តហោះវាទម្លាក់ហ្នឹង នៅបឹងព្រាវស្រែអំបិលយើងហ្នឹង បើអូនទៅស្រែអំបិលស្គាល់ហើយភូមិបឹងព្រាវហ្នឹង គឺយើងនៅមន្ទីរពេទ្យយើងធ្វើនៅមួយកន្លែងសម្រាប់ដាក់របួស ដល់ពេលហើយឆ្នាំ៧៤ហ្នឹងយន្តហោះវា ដូចថាគេញវាស៊ើបការណ៍

ដល់ពេលហើយវាមកទម្លាក់គ្រាប់បែកនៅកន្លែងហ្នឹងហ្នង ដល់ពេលហើយខ្ញុំរត់ ហើយបីអ្នកជម្ងឺ ហើយអ្នកជម្ងឺវាធំយើងវាតូច រត់លូនចូលក្នុងលូ វាទម្លាក់ស្លាប់អស់ពីនាក់ ស្លាប់អ្នកជម្ងឺ១នាក់ ហើយពេទ្យ១នាក់កំពុងលីអ្នករបួសព្រោះយើងជញ្ជូនអត់ទាន់។

ដានី: ហើយមីងរៀនពេទ្យបានរយៈពេលប៉ុន្មានទៅ បានមីងចេញព្យាបាល?

ណៃ: មកដល់នោះដាក់ស្តែង គ្រាន់តែចេញទៅដល់អត់មានបានរៀនបានអីទេ គ្រាន់តែយើងមើលគេហើយ បង១គេប្រាប់ព្រោះយើងវាខ្វះខាតណាស់ ហើយគ្រាន់តែថាចូលទៅដល់អូនឯងមើលបងទៅធ្វើម៉េចអីម៉េច យកថ្នាំមកហើយគឺរៀនចាក់សាច់ដុំចាក់អីហើយធ្វើហ្នង ខ្ញុំគ្រាន់តែមើលគេអញ្ចឹងស្រវ៉ាម្ជុលស្រវ៉ាស៊ីរ៉ាំងចាក់ហ្នង ហើយយប់អញ្ចឹងរៀនទៅវាស់អីមើលអីទៅទាំងអស់គ្នាអញ្ចឹង ដូចថាអ្នករៀនក្រោយរៀនមុខអីហ្នឹង ហើយអ្នករបួសហ្នឹងក៏អញ្ចឹងដែរ ព្យាបាលហ្នឹងគឺរៀនដាក់ស្តែងហ្នង រៀនហើយធ្វើហ្នង ចុះយើងវាខ្វះខាតកាលជំនាន់ហ្នឹង។

ដានី: អញ្ចឹងនៅពេទ្យស្រុកហ្នឹងរហូតដល់ពេលណាទៅ?

ណៃ: រហូតដល់យើងរត់ហ្នឹង។

ដានី: ធ្វើពេទ្យស្រុកពី៧៤រហូតដល់ពេល?

ណៃ: យើងរត់មក ដល់ពេលយើងមុនដំបូងនៅពេទ្យស្រុកហ្នឹងបានប្រហែលជាមួយឆ្នាំ។

ដានី: រហូតដល់៧៥?

ណៃ: អត់ទេ គេរើសយើងមកវិញណាស់ យើងធ្វើការបានល្អអញ្ចឹងណាស់ ដល់ហើយគេយកយើងមកនៅតាមភូមិ ដើរតាមភូមិ ដើរមើលប្រជាជនវិញណាស់ ដើរព្យាបាលតាមភូមិ ហើយខ្ញុំមកនៅតំបន់ភូមិទៀត។

ដានី: ភូមិអីគេ?

ណៃ: នៅស្រែអំបិលហ្នឹងគេហៅភូមិទៀត១ មកនៅកន្លែងតំបន់ហ្នឹង ហើយយើងនៅព្យាបាលអញ្ចឹងណាស់។

ដានី: ឆ្នាំណាដែលមកនៅតំបន់ហ្នឹង?

ណៃ: នៅតំបន់ហ្នឹងឆ្នាំ៧០ យើងរំដោះភ្នំពេញហើយ។

ដានី: រំដោះភ្នំពេញឆ្នាំ៧៥?

ណៃ: ចាស៎! រំដោះឆ្នាំ៧៥ ហើយ៧៦-៧៧យើងចេញមកហ្នឹងហើយ។

ដានី: អញ្ចឹងពេលរំដោះហើយឆ្នាំ៧៥ហ្នឹង មីងនៅពេទ្យស្រុកដដែល?

ណៃ: នៅពេទ្យស្រុកហ្នឹង នៅព្យាបាលហ្នឹងទាំងអស់គ្នាហ្នឹង។

ដានី៖ ហើយ៧៧មកតំបន់?

ណៃ៖ ហ្នឹងហើយមកតំបន់ ។

ដានី៖ គេហៅតំបន់ប៉ុន្មាន?

ណៃ៖ អាហ្នឹងពេទ្យតំបន់គេហ្នុងគេហៅគណៈតំបន់អញ្ចឹងហ្នុង ។

ដានី៖ ប៉ុន្តែតំបន់ប៉ុន្មាន?

ណៃ៖ គេហៅតែមន្ទីរតំបន់ៗហ្នឹង យើងអត់ដឹងដែរ បើគេដាក់អញ្ចឹង ដូចថាកន្លែងស្រុកកន្លែងតំបន់អញ្ចឹងណាំ គេហៅអញ្ចឹង ដល់ពេលអញ្ចឹងយើងមកនៅហ្នឹង មកព្យាបាលប្រជាជន ហើយកាលហ្នឹងគេចាត់តាំង គេធ្វើដូចមានប្រជាជនសហករណ៍ ហើយរើសនារីកងចល័តហ្នឹង ហើយនារីដែលនៅតាមចាត់តាំង អញ្ចឹងក៏យើងមកនៅព្យាបាលតាមភូមិទៅ ហើយយើងដើរគ្រប់កន្លែងទាំងអស់ យើងដើរមើលដូចអូនឯងដើរធ្វើការអញ្ចឹងណាំ ហើយមើលជនណាកន្លែងណាវេទនា ហើយកន្លែងណាអត់វេទនាដើរមើលហ្នុង ដើរ២-៣យប់ យើងគិតតែពីដើរម៉ោ ហើយដើររហូតដល់រត់ហ្នឹង ។

ដានី៖ រហូតដល់ឆ្នាំ៧៩ហ្នុង?

ណៃ៖ ចាំ! កាលឆ្នាំ៧៩យើងចេញ ហើយរត់មកហ្នុង អាហ្នឹងយើងនៅជាប់ជាមួយមេទៀត ។

ដានី៖ កាលហ្នឹងនៅខាងស្រែអំបិលហ្នឹងនៅខាងភូមិភាគណាទៅ

ណៃ៖ នៅខាងបច្ចឹម ។

ដានី៖ នៅភូមិភាគបច្ចឹម?

ណៃ៖ ចាំ! ហើយប្រជាជនដែលនៅភូមិភាគបច្ចឹមហ្នឹងគឺម៉ាជំនាន់៧៦-៧៧ហ្នឹងវេទនាណាស់ គេវៃចោលក៏វៃ ហើយបន្តត់បាយ គឺគណៈតំបន់ហ្នឹងវាក្បត់ ។

ដានី៖ គណៈតំបន់?

ណៃ៖ ហ្នឹងហើយ ឈ្មោះ តាទីន តាទីន ហ្នឹងគាត់ក្បត់ ដូចថាប្រជាជនធ្វើស្រូវបានអញ្ចឹង ដូចថាភូមិយើងនេះអត់ទៅយកពីភូមិអូនឯងមក តែតាមការពិតយកពីភូមិហ្នឹងអត់មានឲ្យប្រជាជនទេ យកទៅចាក់ចោលហ្នឹង វាអញ្ចឹងណាំ ដល់ពេលយកទៅចាក់ចោលហ្នឹងវាចង់ដឹងខុសដឹងត្រូវវាយកកាំបិតមួយឆូតបាវស្រូវហើយទម្លាក់ទៅក្នុងទឹកដើម្បីឲ្យស្រូវវាអណ្តែតឡើងដើម្បីឲ្យគេឃើញ អញ្ចឹងណាំ ហើយបានក្រោយមកគេចាប់គាត់ហ្នឹង ប៉ុន្តែគេចាប់គាត់ហ្នឹង តាទីន ហ្នឹងគេចាប់គាត់ឆ្នាំប៉ុន្មានទេភ្លេចបាត់ហើយ ដូចជាឆ្នាំ៧៨ឬ៧៧ទេខ្ញុំភ្លេចបាត់ហើយ ព្រោះខ្ញុំមិនសូវយកចិត្តទុកដាក់ទេ ហើយគេធ្វើបាបណាស់ប្រជាជន

កុមារ ហើយខ្ញុំចេះតែនឹកអាណិត ដល់ពេលអាណិតគេចង់យកឯងទៅវៃចោលដែរ ប៉ុន្តែយើងធ្វើបានល្អ ។

ដានី: អញ្ចឹងកាលហ្នឹងមីងឆ្នាំ៧៧ហ្នឹងផ្លាស់មកពេទ្យតំបន់?

ណៃៈ អត់ទេ មិនមែនមកពេទ្យតំបន់ទេ យើងមកកន្លែងតំបន់ ។

ដានី: មកកន្លែងតំបន់?

ណៃៈ ចាំ! មិនមែនកន្លែងពេទ្យតំបន់ទេ ពេទ្យតំបន់ហ្នឹងយើងទៅតែមួយដង១ទេ កន្លែងពេទ្យតំបន់ហ្នឹងគឺកន្លែងបឹងព្រាវ ពេទ្យតំបន់ហ្នឹងមួយកន្លែង កន្លែងតំបន់គេហ្នឹងគឺកន្លែងធំហើយអាហ្នឹងសម័យ៧៧-៧៨ហ្នឹង ។

ដានី: នៅបឹងព្រាវ?

ណៃៈ ចាំ! ពេទ្យតំបន់គេនៅកន្លែងហ្នឹង ហើយកន្លែងតំបន់មកកន្លែងប្រជាជន ។

ដានី: មកកន្លែងប្រជាជន?

ណៃៈ ដូចថាយើងមកកន្លែងប្រជាជនដែលឈឺអញ្ចឹង យើងយកថ្នាំយកអង្ករមកចែកឲ្យគាត់ ។

ដានី: ប៉ុន្តែមីងនៅក្នុងអង្គភាពពេទ្យស្រុកដដែលមែន?

ណៃៈ ចាំ! នៅហ្នឹងពេទ្យស្រុកដដែល គ្រាន់តែយើងដើរ យើងដើរហើយយើងនៅ ។

ដានី: ពេទ្យស្រុកច្រើនទេ?

ណៃៈ ពេទ្យស្រុកច្រើនណាស់ ប៉ុន្តែកាលមួយជំនាន់ហ្នឹងក៏ចាប់គ្នាវៃចោលច្រើនទៀត ។

ដានី: អញ្ចឹងចាប់យកទៅវៃចោលច្រើនដែរអញ្ចឹង?

ណៃៈ ចាំ! ក្រោយមកទៀតខ្ញុំដឹង ព្រោះខ្ញុំទៅព្យាបាលនៅកន្លែងកងចល័ត ហើយនៅកន្លែងកងចល័តហ្នឹងគេថាមនុស្សរើសដូចថាធ្វើកងនារីណា គេហៅកងចល័ត១ មានដែលឮឈ្មោះទេ?

ដានី: ឮ ។

ណៃៈ គេថាមនុស្សរំដោះពីភ្នំពេញមកអញ្ចឹង ដែលគេថា១៧មេសានោះ ដល់ពេល១៧មេសាគេយកទៅនៅកងចល័តទាំងស្រីទាំងប្រុស ហ្នឹងហើយដែលគេឲ្យមកលើកទំនប់នៅបឹងព្រាវនេះ គឺស្លាប់អស់ច្រើនណាស់ ហើយអ្នកដែលធ្វើគុកនោះ ឈ្មោះតាអ៊ីទេ ភ្លេចឈ្មោះតាធ្វើប្រធាន ឈ្មោះអ៊ីទេអត់មានចាំបន្តិចសោះ ភ្លេចហ្នង ។

ដានី: ប្រធានគុក?

ណៃៈ ប្រធានគុក គេនៅកន្លែងតំបន់ហ្នឹងណា នៅកន្លែងទំនប់ហ្នឹងឈ្មោះអ៊ី ហើយប្អូនខ្ញុំនៅជាមួយហ្នឹង ហើយគេនៅធ្វើអ៊ីទេ ពីមុនចាំឈ្មោះឥលូវភ្លេចបាត់ហើយ ខ្ញុំដល់ពេលនឹក

អាណិតគេពេកខ្ញុំទៅមើលគេដាក់គុកណា៎ ដល់ពេលទៅមើលគេថា« បងពេទទៅមើលហ្នឹងបែបចង់ចូលខ្លួនឯងហើយមើលទៅ» ហើយខ្ញុំថាមិនមែនទេ ខ្ញុំមកនឹកអាណិតព្រោះសុទ្ធតែជាមនុស្សដូចគ្នា យើងនឹកអាណិតគេណាស់ ដល់ពេលហើយគេយកទៅវ៉ៃចោល ហើយពេទ្យខ្លួនឯងដាក់ស្នែងហ្នឹង ដែលពេទ្យតំបន់ហើយនឹងពេទ្យស្រុកហ្នឹងនៅច្រឡំច្រឡូកជាមួយគ្នា ដល់ពេលក្រោយមកធម្មតាទេ ដូចថាបង១ដែលថាគាត់ចាស់មកយូហើយ គាត់ស្រលាញ់គ្នាណាស់អុន ហើយយើងកាលនោះនៅតូចៗទេ ដល់ពេលស្រលាញ់គ្នាទៅវាខុចសិលធម៌ ដល់ពេលស្រលាញ់គ្នាយកធ្វើប្ដីប្រពន្ធហ្នឹង យកគ្នាទៅអញ្ជឹងទៅវ៉ៃប្ដីចោលអណ្ដែតតាមទឹកប្រឡាយ ហើយមនុស្សស្រីហ្នឹងគេវះយកមក អាហ្នឹងខ្ញុំឃើញដាក់ស្នែង ។

ដានី: គេវះម៉េច?

ណៃ: គេវះយកកូន ។

ដានី: គេវះពោះយកកូន?

ណៃ: ចា៎! គេវះពោះយកកូន ពួកអាយោធាហ្នឹង ។

ដានី: ឆ្នាំណា?

ណៃ: ឆ្នាំ៧៧ហ្នឹងហ្មង ។

ដានី: ៧៧?

ណៃ: ចា៎!

ដានី: គាត់ឈ្មោះអីពេទ្យហ្នឹង?

ណៃ: ឈ្មោះ បងវ៉ាន ។

ដានី: បងវ៉ាន ហ្នឹងពេទ្យស្រី?

ណៃ: ចា៎! ពេទ្យស្រី ។

ដានី: ហើយចុះប្រុស?

ណៃ: ប្រុសហ្នឹងខ្ញុំអត់ស្គាល់ទេ គាត់ស្រលាញ់គ្នាជាមួយយោធាហ្នឹងគេចាប់វ៉ៃទៅ ។

ដានី: នៅពេទ្យជាមួយមីងមែន?

ណៃ: ធ្លាប់នៅជាមួយគ្នា ។

ដានី: ធ្លាប់នៅពេទ្យស្រុកជាមួយគ្នា?

ណៃៈ នៅពេទ្យស្រុក ពេទ្យឃុំជាមួយគ្នា ដើរធ្វើការ ហើយមនុស្សធ្លាប់វេទនាជាមួយគ្នា ដល់ពេលខុសសិលធម៌ គាត់ស្រលាញ់គ្នា ដល់ពេលថាមានកូនគាត់ស្រលាញ់គ្នាអញ្ចឹងគេយកគាត់ទៅវះក្នុងទឹកប្រឡាយ ។

ដានីៈ ទឹកប្រឡាយយោធាហ្នឹង?

ណៃៈ វះទឹកប្រឡាយហ្នឹងគេលើកទំនប់ធំណាស់ ទំនប់ស្រែអំបិលបឹងព្រាវនៅរាល់ថ្ងៃហ្នឹង ដល់ពេលអញ្ចឹងគេអាមុខទឹកអញ្ចឹងហូរទៅគេវះខាងក្រោម គេយកទៅវះខាងក្រោម ។

ដានីៈ ខាងណាអ្នកវះ ខាងយោធាមែន?

ណៃៈ ខាងយោធា ។

ដានីៈ យោធាមកពីណាមក?

ណៃៈ យោធានៅតំបន់ហ្នឹងដែរ ដល់ពេលខ្ញុំនឹកឃើញថា ប្អូនខ្ញុំ ពុកខ្ញុំបែបគេយកទៅធ្វើបាបអញ្ចឹងដែរមិនដឹង ព្រោះឪពុកខ្ញុំគេយកទៅវៃចោលឆ្នាំ៧៧ហ្នឹងដែរ ។

ដានីៈ ឪពុកមីងគេយកទៅវៃចោលឆ្នាំ៧៧ហ្នឹងដែរ?

ណៃៈ ហ្នឹងហើយ ដូចថាគាត់ហ្នឹងគាត់ធ្វើមេគេដែរណា៎ គាត់ធ្វើប្រធានភូមិអញ្ចឹងណា ដល់ហើយគេចង់ធ្វើធំដែរ ដល់ហើយគេដណ្តើមគាត់ គាត់អ្នកធ្វើល្អតែគេចោទគាត់ថាគាត់ហ្នឹងខូចសិលធម៌ ថាឪពុកខ្ញុំហ្នឹងខូចសិលធម៌ តែតាមការពិតអត់ផងហ្នឹង ហើយគេចោទដល់ពេលអញ្ចឹងគេចាប់គាត់យកទៅវៃចោល ។

ដានីៈ អាហ្នឹងឆ្នាំ៧៧ហ្នឹង?

ណៃៈ ចា៎! ហើយកូនខ្ញុំដែលថាខ្ញុំដាក់គ្រូកូលហ្នឹង គាត់ចាស់ៗហើយ ។

ដានីៈ កុងឈ្មោះ ព្រំ ហ្នឹង?

ណៃៈ ចា៎! គេឲ្យយកទៅមើលគោ ចាស់ៗ៨នាក់យកទៅមើលគោ ហើយស្រុកខ្ញុំសំបូរព្រៃហើយសំបូរខ្លាទៀត ខាងកោះកុងស្រែអំបិលហ្នឹងសុទ្ធតែព្រៃហើយអត់មានវាលទេ ហើយគេយកគាត់ទៅឃ្វាលគោវាបាត់គោ ដល់ពេលបាត់គោ បាត់កូនគោ២-៣អញ្ចឹងដល់ហើយគេថាគាត់ហ្នឹងវៃស៊ី ចាប់គាត់យកទៅវៃចោលឲ្យស៊ីស្លឹកអំពៅ ។

ដានីៈ ឲ្យស៊ីស្លឹកអំពៅ?

ណៃៈ ចា៎! ដល់ពេលឲ្យស៊ីស្លឹកអំពៅប្អូនជីដូនមួយខ្ញុំវាលបមើលឃើញហើយវាមកប្រាប់ខ្ញុំ ថាថែៗ កុងគេយកទៅវៃចោលហើយ ខ្ញុំទៅលបមើល ហើយចាស់ៗហ្នឹងគេឲ្យស៊ីស្លឹកអំពៅហើយគេវៃចោលនៅព្រៃអំពៅហ្នឹងទៅ ហើយឲ្យស៊ីស្លឹកអំពៅឲ្យអស់មួយបាច់ ហើយស៊ីមានអស់ណា គេវៃចោល គេធ្វើបាប ពួកអាធ្វើអំពើរអាក្រក់ហ្នឹង ។

ដានី:	ពួកណាអ្នកវ៉ៃ?

ណៃ:	ពួកឈ្លបគេហ្នឹង ពួកឈ្លបនៅក្នុងស្រុកភូមិហ្នឹងហ្នង ។

ដានី:	នៅក្នុងស្រុកភូមិគេហ្នឹង?

ណៃ:	ចា៎! គឺឆ្នាំ៧៧ហ្នឹងហ្នង ។

ដានី:	នៅក្នុងភូមិណា?

ណៃ:	នៅស្រុកស្រែអំបិលហ្នឹងហ្នង នៅស្រុកដែលនៅភូមិដងពែងហ្នឹង ប៉ុន្ដែមនុស្សគេអ្នកធ្វើឈ្លបហ្នឹងមិនដឹងគេមកពីណាទេ ហើយមកនៅក្នុងស្រុកភូមិយើងហ្នឹង ហើយប្រជាជនស្រុកខ្ញុំសំបូរព្រៃណាស់ ហើយត្រីហ្នឹងគេអត់ឲ្យហូបទេ ។

ដានី:	ម៉េចអញ្ចឹង?

ណៃ:	ធ្វើបាបប្រជាជនណាស់ ខ្ញុំនៅប្រឡូកនៅហ្នឹងខ្ញុំដឹង ខ្ញុំដើរធ្វើ ប៉ុន្ដែស្រុកភូមិគេខ្លះអត់វេទនាទេ ស្រុកភូមិម៉ុខាងខ្ញុំគឺវេទនាហ្នង វេទនាគេធ្វើបាបសម័យ៣ឆ្នាំហ្នឹង ប៉ុន្ដែមិនដឹងថាអ្នកណាធ្វើបាប អត់ដឹង តែការពិតគឺឈ្លបភូមិឈ្លបឃុំហ្នឹងហ្នង នៅហ្នឹងគេធ្វើបាបអត់មានអ្នកណាមក ធ្វើបាបអត់មានឲ្យបាយប្រជាជនហូបឆ្អែតទេ ឲ្យ១វែកៗ ។

ដានី:	ឲ្យតែ១វែកៗទេ?

ណៃ:	ចា៎!

ដានី:	ហើយចុះមីងធ្វើពេទ្យបានហូបឆ្អែតអត់?

ណៃ:	យើងធ្វើពេទ្យមិនយ៉ាប់ដូចប្រជាជនទេ ព្រោះអត់អីទេ មានតាមថ្នាក់ បើថាហូបបបរគឺបបរមួយកន្ទន់ទៅ ហើយមានត្រីមានសម្លរអញ្ចឹងទៅ មានត្រីខ ត្រីចំហុយហូបទៅ ដល់ពេលប្រជាជនបាយទឹកពរកែកក្ដក១វែក ហើយបើក្មេងប៉ុនៗនេះដឹងតែអត់ហើយ ។

ដានី:	អញ្ចឹងធ្វើពេទ្យយើងបានហូបគ្រប់គ្រាន់?

ណៃ:	ចា៎! បានហូបគ្រាន់បើ បើយើងដើរមើលបានខ្ញុំអាណិត នឹកឃើញវេទនាណាស់ ប្អូនខ្ញុំវេទនាណាស់ទម្រាំបានរស់ដល់សព្វថ្ងៃហ្នឹង វាលុតដំណាស់ ។

ដានី:	ចុះមីងកាលធ្វើពេទ្យហ្នឹងអាសារបានទៅលេងផ្ទះទេ?

ណៃ:	អត់បានទៅទេ ។

ដានី:	អត់មានបានទៅទេ?

ណៃ:	ហ្នឹងហើយអត់បានទៅទេ យើងអត់មានសុំច្បាប់គេ កាលហ្នឹងទៅបានម្ដងគត់ បានទៅជួបជីដូនហ្នឹងម្ដង ហើយអត់មានបានជួបម្ដាយទៀត ជួបតែជីដូនហ្នឹង ពេលជីដូនហ្នឹង

ស្លាប់នៅជាមួយប្អូនតូចៗ ពេលស្លាប់ហ្នឹងវាប្រាប់ថា គាត់អត់មានបាយហូបទេគាត់ឈឺ ហើយផ្ទះធំគេអត់ឲ្យនៅទេ គេឲ្យនៅកូនខ្ទមតូច ។

ដានី: គេឲ្យនៅកូនខ្ទមតូច?

ណៃ: ចាំ! ផ្ទះខ្ញុំលើកមុនធំ តែគេរុះធ្វើសហករណ៍ ។

ដានី: ចុះមីងដែលយើងដើរមើលព្យាបាលប្រជាជនតាមកងចល័ត កាលហ្នឹងប្រជាជនភាគច្រើនឈឺអីគេ?

ណៃ: ឈឺជម្ងឺដូចជា គ្រុនចាញ់អញ្ចឹងទៅ ដូចថាខ្យល់ចាប់ ចុកពោះ ឬក៏គ្រុនក្តៅអញ្ចឹងទៅ វាអត់មានជម្ងឺអីទេ យើងជម្ងឺអត់បាយហ្នឹងហ្នង យើងហូបបាយអត់គ្រប់គ្រាន់ ហើយខ្ញុំទៅព្យាបាលគេហ្នឹងដែលដើរតាមភូមិហ្នឹង ប្រជាជន៧៦-៧៧ហ្នឹងគេលើកទំនប់ហ្នឹងយើងមកព្យាបាលនៅបឹងព្រាវនៅកន្លែងលើកទំនប់នេះ ហើយយើងដើរតាមភូមិហ្នឹងហូបវាអត់គ្រប់គ្រាន់ ។

ដានី: មានជម្ងឺម៉េចទៅ?

ណៃ: ជម្ងឺរាគ ហើយនឹងហើម ដូចប៉ុនៗហ្នឹងអីរាគហើយ ជម្ងឺទូទៅរាគហ្នង ហើយហូបមិនគ្រប់គ្រាន់ហើយដេកកុមារគេយកមកដាក់មួយកន្លែង ហើយពេលដេកវាអាចម៍នោមពេញហ្នឹងទាំងអស់ វេទនាណាស់គេយកមកដាក់កន្លែងកណ្តុរគេហៅកន្លែងកុមារ គេយកមកដាក់កន្លែងកុមារ ហើយអាតូចៗប៉ុននេះមិនទាន់បាត់ជៅដោះក៏គេយកមកដាក់នៅកន្លែងកុមារដែរ ហើយដល់ពេលមេៗគេ ឈ្លបភូមិ ឈ្លបឃុំគេ គេសុទ្ធតែដើរពិនិត្យមើល អ្នកណាធ្វើអីអ្នកណាមិនធ្វើអីគេចាប់យកទៅវៃចោល ហើយព្រៃសំបូរណាស់ស្រុកខ្ញុំ តែគេអត់ឲ្យហូបទេ ដោយឡែកដោយយើងនៅពេទ្យហ្នឹងវាគ្រប់គ្រាន់ ហើយប្រជាជនគឺយ៉ាប់ណាស់ សហករណ៍គេហ្នឹងគឺមេគេអ្នកដឹកនាំ ប៉ុន្តែមេគេហ្នឹង មេឈ្មោះ តាសានៗ គេចាប់យកទៅ កាលហ្នឹងគាត់ធ្វើឃុំ គាត់ធ្វើឃុំធ្វើគណៈស្រុកហ្នឹង ។

ដានី: នៅពេលណា?

ណៃ: នៅពេលឆ្នាំ៧៦-៧៧ហ្នឹងគេចាប់ទៅវៃចោល ។

ដានី: គណៈស្រុកស្រែអំបិលហ្នឹងឈ្មោះអី?

ណៃ: គណៈស្រុកស្រែអំបិលខ្ញុំភ្លេចឈ្មោះបាត់ហើយ ដូចជាឈ្មោះអីទេ តែស្គាល់តែគណៈតំបន់ ។

ដានី: គណៈតំបន់ឈ្មោះអី?

ណៃ: ឈ្មោះ តាទីន ។

ដានីៈ គាទីន?

ណៃៈ ចា៎! គាទីន តែគណៈស្រុកខ្ញុំអត់ស្គាល់ទេភ្លេចបាត់ហើយ ។

ដានីៈ ចុះឈ្មោះអីមួយទៀត?

ណៃៈ ឈ្មោះ គាសល់ គាត់ហ្នឹងកាល៧៩គាត់ខ្លាចខ្ញុំតើ នៅជំរុំអូរ គាត់អផ្សុរព្រោះគាត់ធ្វើខុស ដល់ពេលគាត់ជួបមុខខ្ញុំគាត់ខំធ្វើនយោបាយហ្នឹង ប៉ុន្តែខ្ញុំនឹកឃើញខ្ញុំមិនសងសឹកទេ ពុទ្ធ ទំនាយខ្ញុំថាម៉េចគឺអញ្ចឹងចុះ ។

ដានីៈ ចុះគាត់ឃើញមីងនៅជំរុំ?

ណៃៈ ចា៎! ជួបនៅជំរុំ ពេលដែលខ្ញុំទៅជំរុំ គាសល់ ហ្នឹងធ្វើបាបប្រជាជនណាស់ ហើយដល់ពេលគាត់ជួបខ្ញុំដូចថាខ្ញុំធ្វើយ៉ាងម៉េចអីយ៉ាងម៉េចណា៎ គាត់ដឹងហើយគាត់ខំធ្វើនយោបាយ ប៉ុន្តែខ្ញុំដឹងតាហ្នឹង គាត់ដឹងតែខ្ញុំទៅជំរុំហ្នឹងខ្ញុំធ្វើដូចថា ខ្ញុំមិនមែនសងសឹក ខ្ញុំមិនធ្វើអីទេ អ្នកណាធ្វើអំពើរអាក្រក់អ្នកហ្នឹងទទួលចុះ ខ្ញុំនិយាយប្រាប់ត្រង់ចុះខ្ញុំអត់មានសងសឹកទេ ប៉ុន្តែបើតាមចិត្តពេលដែលគាត់មកកាន់កាប់ហ្នឹងគឺយ៉ាប់អញ្ចឹងហ្នុង ឈ្មោះ តាសាំង មក កាន់នៅភូមិហ្នឹង ក្រោយមក តាសល់ ហ្នឹង តាសល់ ហ្នឹងនៅបានប៉ុន្មានក្រោយមករត់ ហ្នុង ។

ដានីៈ គាត់ហ្នឹងមកពីខាងណា?

ណៃៈ គាសល់ ហ្នឹងខ្ញុំអត់ដែលស្គាល់ទេ មិនដឹងនៅណាទេមនុស្សហ្នឹង មិនដឹងមកពីខេត្តណាទេ ។

ដានីៈ ប៉ុន្តែមកជួបគ្នានៅជំរុំ?

ណៃៈ មកជួបគ្នានៅជំរុំ តែគាត់មកធ្វើការកាន់កាប់នៅស្រុកស្រែអំបិលហ្នឹងហ្នុង គាត់មកខាងឃុំ ដូចថាគាត់មកកាន់ឃុំអញ្ចឹង គាត់កាន់ឃុំដងពែង ហើយប្រពន្ធគាត់ឈ្មោះ អ៊ិត ដល់ពេល ខ្ញុំទៅជួបគ្នា ហើយខ្ញុំចំណាំគាត់បាន ហើយគាត់ហ្នឹងក៏ចំណាំខ្ញុំបានដែរ ព្រោះខ្ញុំធ្វើការខ្ញុំ ដឹង ចុះយើងធ្វើល្អយើងណែនាំយើងនិយាយពេលយើងប្រជុំប្រជាជនយើងពេទ្យៗណា៎ យើងទៅធ្វើការអញ្ចឹង គាត់ដឹងថាយើងធ្វើម៉េចៗ គាត់ដឹងថាខ្លួនគាត់ធ្វើអាក្រក់ខ្ញុំធ្វើ នយោបាយណាស់ ។

ដានីៈ គាត់ធ្វើម៉េច?

ណៃៈ គាត់ថា.. មិនដឹងគាត់ធ្វើម៉េចទេ ព្រោះខ្ញុំមិនដែលនិយាយរកគាត់ ដូចថារបៀបថាដឹងខ្លួន ណា៎ ខ្លាចខ្ញុំប្រាប់ ព្រោះខ្ញុំទៅដល់ជំរុំពូខ្ញុំគាត់ធ្វើប្រធានជំរុំ ពូខ្ញុំគាត់វេទនាណាស់ ដល់ ពេលគាត់ទៅដល់ជំរុំគាត់ចេះថៃ គាត់ចេះភាសាអង្គ្លេសដូចប៉ាខ្ញុំអញ្ចឹង ដល់ហើយគាត់ធ្វើ ប្រធានជំរុំ តែឥលូវគាត់ទៅប្រទេសអាមេរិចបាត់ហើយ ។

ដានី៖ គាត់នៅអាមេរិច?

ណៃ៖ ចា៎! ពូខ្ញុំគាត់ទៅអាមេរិចបាតហើយ គ្រួសារខ្ញុំក៏ស្គាល់ដែរ ឈ្មោះពូ វរៈ មុនគាត់នៅកងចល័ត ដល់ពេលគាត់ទៅហ្នឹងមុនគេធ្វើបាបគាត់ណាស់ពេលទៅនៅកងចល័ត ដល់ពេលក្រោយមក គាត់ហ្នឹងចិនដែរ ដល់ហើយមុនដំបូងគាត់ចេះថៃ ដល់ពេលចេះថៃគេលើកឲ្យនិយាយដល់ហើយគេឲ្យធ្វើប្រធានជំរុំណា៎ ដល់ពេលដឹងថាអញ្ចឹងពូ សល់ ហ្នឹងខ្លាច ទំស្គរ ខ្ញុំ រាក់ទាក់ខ្ញុំអូននេះអូននោះ ហើយខ្ញុំក៏អត់មាត់ដែរ ខ្ញុំថាមនុស្សធ្វើបាបគេពីមុន ខ្ញុំនិយាយដែរហ្នឹង គាត់ហូបកាហ្វេអញ្ចឹងហើយខ្ញុំហូបគុយទាវជិតគ្នា ខ្ញុំនិយាយថាពីមុនមកមនុស្សធ្លាប់ធ្វើបាបគេចាំមើលថ្ងៃក្រោយពៀរវាឆ្លងហើយ ពីសម័យឆ្នាំយើងដែលនៅស្រុកថៃ ខ្ញុំថាអញ្ចឹង ឥលូវកាលពីមុនមកនៅស្រុកខ្មែរ ខ្ញុំថាអ្នកនៅស្រុកខ្មែរអ្នកធ្លាប់ធ្វើប្រធានឃុំប្រធានភូមិ វៃមនុស្សចោលផុយណាស់ ចាំមើលមកដល់ស្រុកថៃហើយតើវាហ៊ានវៃទៀតអត់ខ្ញុំថាអញ្ចឹង ចាំមើលវាហ៊ានអ៊ឹតក្បាលឲ្យថៃដាក់ហើយ ដល់ហើយខ្ញុំនិយាយភាសាថៃជាមួយពូខ្ញុំ ហើយពូខ្ញុំក៏គាត់និយាយភាសាថៃដែរ ដល់ពេលអញ្ចឹងគាត់ខ្លាចតាំងពីនោះមក ដល់ក្រោយមកខ្ញុំចេញមកបាត់មក មិនដឹងគាត់ទៅណាវិញ ខ្ញុំឡើងមកលើវិញមក ។

ដានី៖ ចុះកាលគេចាប់ឪពុកមីងទៅសម្លាប់ មីងដឹងដែរ?

ណៃ៖ អត់ដឹងគេចាប់ឪពុកទៅផង ព្រោះយើងចេញធ្វើបដិវត្តន៍បាត់ហើយ ព្រោះយើងចេញទៅឆ្ងាយ ។

ដានី៖ យើងចេញទៅឆ្ងាយ?

ណៃ៖ ចា៎! យើងធ្វើពេទ្យយើងចេញទៅឆ្ងាយ ។

ដានី៖ ចុះមីងមានតួនាទីអីធ្វើពេទ្យហ្នឹង?

ណៃ៖ អត់មានតួនាទីអីផង ធ្វើពេទ្យធម្មតា ។

ដានី៖ ធ្វើពេទ្យធម្មតា?

ណៃ៖ ចា៎! ពេទ្យអត់មានតួនាទីអីទេ ។

ដានី៖ ហើយមីងធ្វើពេទ្យហ្នឹងរហូតអត់មានទៅរៀនទេ?

ណៃ៖ អត់មានទៅរៀនណាទេ ធ្វើតែពេទ្យនៅហ្នឹង ។

ដានី៖ អត់មានទៅភ្នំពេញទេ?

ណៃ៖ ទៅ! ទៅភ្នំពេញទៅធ្វើការ ទៅយកថ្នាំពេទ្យយកអីអញ្ចឹងដែរហ្នឹង ។

ដានី៖ ធ្លាប់ទៅយកថ្នាំពេទ្យនៅភ្នំពេញដែរ?

ណៃៈ ទៅ! កាលទៅយកថ្នាំពេទ្យនៅឆ្នាំ៧៦ ទៅយកថ្នាំពេទ្យនៅភ្នំពេញ យើងរំដោះភ្នំពេញ ហើយយើងទៅយកថ្នាំនៅភ្នំពេញ ហើយជួបជាមួយគា ជួន ជឿន ណា៎ ។

ដានីៈ ជួបគាត់នៅណា?

ណៃៈ ជួបគាត់នៅសម័យ៣ឆ្នាំ ជួបគាត់នៅភ្នំពេញហ្នឹងឯង ដល់ពេលក្រោយមកទៀត ខ្ញុំយកគ្រួសារខ្ញុំហើយខ្ញុំទៅដេកពេទ្យហ្នឹងក៏ជួបគាត់ទៀត ហើយយើងធ្លាប់ធ្វើពេទ្យជាមួយគាត់ គាត់ដឹងថាសម្ភារៈហ្នឹងខ្ញុំយកគ្រួសារខ្ញុំហ្នឹងអស់ពីខ្លួនហើយ ដែលសម្ភារៈដែលធ្វើពេទ្យហ្នឹង ព្រោះខ្ញុំរៀនពេទ្យហ្នឹងខ្ញុំឆ្មបផង ខ្ញុំចេះឆ្មប ហើយមកដល់សព្វថ្ងៃនេះក៏ចេះឆ្មបដែរ គេមានឋបស័ក្តយ៉ាងណាទៅនៅកន្លែងស្រុកហ្នឹងហើយ ប៉ុន្តែក្របខ័ណ្ឌធ្វើហ្នឹងនៅជាប់ហ្នឹងស្រុកហ្នឹងដែរ ។

ដានីៈ ឥលូវហ្នឹង?

ណៃៈ ចា៎! ប៉ុន្តែគ្រាន់តែថាពេទ្យភូមិយើងប្រចាំភូមិ ប៉ុន្តែនិសិត្សហ្នឹងយើងចប់នៅក្នុងស្រុកហ្នឹងដែរ ប៉ុន្តែខ្ញុំអត់ចូលប្រចាំថ្ងៃ អាហ្នឹងខ្ញុំនៅក្នុងភូមិ អាហ្នឹងពេទ្យឆ្មប ។

ដានីៈ ពេទ្យឆ្មប?

ណៃៈ ចា៎! ពេទ្យឆ្មប ។

ដានីៈ ចុះកាល៣ឆ្នាំមីងមិនមែនពេទ្យឆ្មបទេ?

ណៃៈ ព្យាបាលក៏ព្យាបាល ឆ្មបក៏ឆ្មប ចេះតាំងពីជំនាន់ហ្នឹងមក ។

ដានីៈ ចេះតាំងពីជំនាន់ហ្នឹងមក?

ណៃៈ ចេះតាំងពីជំនាន់នោះមក គិតទៅប្រហែលជាអាយុ១២-១៣ហ្នឹងមករហូត មកទល់គ្រាន់តែចាប់ធ្វើពេទ្យហ្នឹងមករហូត ចាប់ធ្វើពេទ្យហ្នឹងហើយសព្វគ្រប់ទាំងអស់ទូទៅទាំងអស់ទៅព្យាបាលរបួស ឆ្មបហ្នឹងក៏កើតគេក៏កើត ធ្វើមួយចប់ហ្នុង ។

ដានីៈ ចុះមីងកាលជំនាន់ហ្នឹងមីងធ្លាប់ឃើញគេសម្លាប់ច្រើនទេ?

ណៃៈ ឃើញគេសម្លាប់ច្រើននៅកងចល័ត ធ្វើស្រែហ្នឹងមេគេដូចថាអូនឯងប្រធានកងចល័តអញ្ចឹង ហើយកុមារតូចៗគេនៅធ្វើអញ្ចឹង បើធ្វើមិនល្អគេអូសដៃវៃចោលកប់ហ្នឹងគល់ដូងហ្នឹងហ្នុង ។

ដានីៈ អញ្ចឹង?

ណៃៈ អាហ្នឹងមីងឃើញផ្ទាល់ភ្នែកហ្នុង ហើយគេចងទាំងខ្សែៗ វៃប៉ុន្តែយើងអត់ហ៊ានធ្វើអីគេទេ គេចងមនុស្សប្រុសនឹងធាងត្នោត ធាងត្នោតប្រវែងហ្នឹង ធាងត្នោតប៉ុនកដើងវៃឡើងរិច ហើយយើងអត់ហ៊ានមើលគេទេ ស្រក់ទឹកភ្នែកព្រោះអាណិតគេ យើងទៅពួនហើយ ។

ដានី: ចុះមីងឃើញផ្ទាល់ភ្នែកហ្នង?

ណៃ: ឃើញផ្ទាល់ភ្នែកហ្នង ។

ដានី: នៅណា?

ណៃ: នៅក្នុងភូមិទៀតហ្នឹងហ្នង ។

ដានី: នៅភូមិទៀត?

ណៃ: ចាំ! នៅភូមិដងពែង ភូមិទៀតហ្នឹង ។

ដានី: ជិតគ្នាមែន?

ណៃ: ចាំ! ភូមិដងពែងហើយនឹងភូមិទៀតហ្នឹងជិតគ្នាតើ ។

ដានី: មូលហេតុអីបានជាគេវ៉ៃ?

ណៃ: មូលហេតុដូចថានៅកងចល័តហ្នឹងអត់បាយហូប ដល់ពេលអត់បាយហូបអញ្ចឹងទៅគ្នាដើរទៅនេះទៅនោះដើម្បីរកដំឡូងរកអីហូប កាលហ្នឹង៧៦-៧៧ហើយដើររកដំឡូង ហើយវាដើរទៅក្នុងព្រៃវាអត់ធ្វើការ ចុះគេធ្វើការលើកទំនប់ ជីកប្រឡាយ ហត់ណាស់អុន ដល់ពេលអញ្ចឹងគេអត់ឲ្យហូបឆ្អែត អញ្ចឹងវាគេច វាគេចទៅរកហូបអញ្ចឹងណាំ ដល់ពេលគេចាប់បានឈ្លបគេហ្នឹង កងនារីគេហ្នឹងដែលជាមេៗប្រធានគេហ្នឹងកង៨៨នារីគេហ្នឹង ដល់ហើយគេចាប់បានគេចងទៅ ហើយគេវ៉ៃទៅ ធាងត្នោតប៉ុនកដើងហ្នឹងវ៉ៃឡើងរិចហ្នង នារីហ្នឹងអ្នកវ៉ៃ គេវ៉ៃយុទ្ធជនហ្នឹង ប្រុសៗហ្នឹងមាឌធំៗដែរហ្នឹង ។

ដានី: នារីហ្នឹងអ្នកវ៉ៃ?

ណៃ: ចាំ! នារីហ្នឹងអ្នកវ៉ៃ សុទ្ធតែស្រីជាអ្នកចាប់ហ្នឹង ប៉ុន្តែពីមុនគេហៅទ័ពកង៨៨ អូនដែលឮទេ?

ដានី: អត់ដែលទេ ។

ណៃ: អត់ដែលទេ?

ដានី: បាទ!

ណៃ: គេហៅនារីកង៨៨ហ្នឹង ។

ដានី: ហើយចាប់យុទ្ធជនប្រុសៗហ្នឹង?

ណៃ: ប្រុសក៏ដោយស្រីក៏ដោយ គេចាប់បានគេវ៉ៃទាំងអស់ ។

ដានី: វ៉ៃហើយគេយកទៅណា?

ណៃ: វ៉ៃហើយមិនដឹងគេយកទៅណាទេ ព្រោះយើងអត់មានបានសួរដែរ គេវ៉ៃហើយឃើញគេយកទៅបាត់ទៅ បែបគេសម្លាប់ចោលមិនដឹង ។

ដានី:	ពេលវៃហ្នឹងមានស្លាប់អត់?

ណៃ:	ពេលវៃហ្នឹងគេចងដៃជាប់គ្នា អត់ស្លាប់ឥលូវទេ ដូចថាជាប់ដៃអញ្ជឹងគេវ៉ៃរះតែម្ដង គេវ៉ៃទាល់តែរិចអាធាងត្នោតហ្នឹងហ្មង អាហ្នឹងមិនឃើញនៅមុខហ្នឹងហ្មង មិនឃើញអញ្ជឹងមិនក៏ចេញទៅ អាហ្នឹងគេធ្វើបាបអញ្ជឹង ហើយមិនដឹងពីខាងលើណាមកគេប្រជុំ មិនដឹងថ្នាក់ណាមកគេបង្គាប់ឲ្យធ្វើអញ្ជឹង ប្រហែលជាចេតនាខ្លួនគេហ្នឹងហ្មង ។

ដានី:	ឆ្នាំណាហ្នឹង?

ណៃ:	ឆ្នាំ៧៧-៧៨ហ្នឹង ឆ្នាំ៧៧ហ្នឹងគឺខ្លាំងហ្មង ដើម៧៨ហ្នឹងក៏សម្បើមដែរ សម្លាប់ចោលហ្មង ហើយចាស់ជរាដែលអត់បាយហ្នឹងគឺងាប់ហ្នឹងអត់បាយហ្នឹងច្រើនណាស់ ប៉ុន្តែមិនដឹងគេយកទៅវៃចោល យកក្ដាមមួយក៏គេវៃចោលដែរ ព្រោះយាយតាយើងគាត់ស្លាប់មិនអត់បាយទាំងអស់គ្នា ក្រុមគ្រួសារខ្ញុំវេទនាណាស់ ។

ដានី:	អញ្ជឹងជិនាន់ហ្នឹងគ្រួសាររបស់មីង ឪពុកគេយកទៅសម្លាប់?

ណៃ:	ចា៎! ឪពុកគេយកទៅវៃចោល តាក៏គេយកទៅវៃចោល ប្អូនក៏គេយកទៅវៃចោល ។

ដានី:	ខុសអីបានជាគេយកទៅវៃចោល?

ណៃ:	ប្អូនខ្ញុំទៅកាប់ផ្ដៅកាលយើងត្រូវរ៉ូវគ្នាហើយណា៎ ខ្មែរក្រហមមិនទាន់ត្រូវខ្វះទេ យើងទៅធ្វើការនៅក្នុងអញ្ជឹង ដល់ពេលប្អូនខ្ញុំវាកាប់ផ្ដៅ ខាងកោះកុងប្រើទូកណា៎ ដល់ពេលកាប់ផ្ដៅអញ្ជឹង ដល់ពេលពួកខ្មែរក្រហមឬក៏មិនដឹងពួកណាទេ វារកស៊ីដូចគ្នាតែមិនដឹងអីទេ ប៉ុន្តែគេថាគេមានកាំភ្លើង ហើយគេហៅយកទៅវៃចោល គេឲ្យយើងឈប់ទូកណា៎ ហើយគេសួរថាអ្នកណាមេដៃ ហើយប្អូនខ្ញុំហ្នឹងវាឆ្លើយថាបងខ្ញុំជាមេដៃ ព្រោះនៅក្នុងទូកវាមានមេដៃនឹងកូនដៃ គេហៅអញ្ជឹងស្រុកហ្នឹង ដល់ហើយគេយកមេដៃទៅវៃចោលហ្មង ។

ដានី:	ឈ្មោះអីប្អូនមីង?

ណៃ:	ប្អូនខ្ញុំឈ្មោះ ដេត ។

ដានី:	នៅណាពេលវៃចោល?

ណៃ:	ពេលវៃចោលនៅអុកតាមៀកនេះ ។

ដានី:	អុកតាមៀកនៅណា ។

ណៃ:	អុកតាមៀកនៅខ័ណ្ឌកោះកុង ។

ដានី:	គាត់បើកទូកទៅណា?

ណៃ:	គាត់បើកទូកទៅកាប់ផ្ដៅ ។

ដានី:	កាប់ផ្ដៅ?

ណៃ: ចាំ! កាប់ផ្តៅយកមកលក់ណាំ ។

ដានី: ឆ្នាំណាហ្នឹង?

ណៃ: អាហ្នឹងមិនដឹងឆ្នាំណាទេ ខ្ញុំភ្លេចសួរប្អូនខ្ញុំ មិនដឹងឆ្នាំណាគេវ៉ៃប្អូនខ្ញុំ ប្អូនខ្ញុំមីស្រីហ្នឹងវាប្រាប់ថាគេវ៉ៃអាហ៊ាចោល ទៅកាប់ផ្តៅជាមួយប្អូនថ្លៃ ជាមួយប្តីមីមួយថាប្រាប់ខ្ញុំ អាណោចអាធម្មណាស់ខ្ញុំ រឿងខ្ញុំគឺច្រើនណាស់គេធ្វើបាប ។

ដានី: អញ្ចឹងដូចអ្នកធ្វើពេទ្យជាមួយគ្នាហ្នឹងឈ្មោះ វ៉ាន ហ្នឹងគេវះពោះ?

ណៃ: ចាំ! គេវះពោះនៅក្នុងប្រឡាយទឹកហ្នឹងហ្នង ។

ដានី: អាហ្នឹងពួកកងទ័ពយោធាគេអ្នកសម្លាប់?

ណៃ: កងទ័ពយោធាគេអ្នកសម្លាប់ហ្នង ទ័ពស្រុកគេហ្នង ឈ្មោះតាអីទេទ័ពស្រុកហ្នឹង រកនឹកអត់ឃើញទេ កាលពីមុនចាំ នៅកន្លែងទំនប់បឹងព្រាវហ្នឹងហ្នង ទំនប់ហ្នឹងនៅដល់រាល់ថ្ងៃនេះធំណាស់ គ្រាន់តែទទឹងជិតប៉ុនផ្ទះហ្នឹង ហើយទំនប់ហ្នឹងខ្ពស់ណាស់ កម្លាំងពីណាៗមកមូលនៅទំនប់ហ្នឹង ហើយងាប់មួយថ្ងៃមិនចេះតិចទេ ហើយអ្នកទោស ឧទាហរណ៍ថាអ្នកទោសហ្នឹងវា១០នាក់អញ្ចឹងសុទ្ធតែចងខ្សែម្នាក់មួយៗ ចងអញ្ចឹងហើយគេបណ្តើរឲ្យទៅកាប់ដីដាក់ឲ្យពេញមួយបង្គីរហើយឲ្យអូសឡើងទំនប់ហ្នឹងទៅ អ្នកណាឡើងមិនរួចគេវ៉ៃពីក្រោយ វ៉ៃឲ្យឡើងលើទំនប់ហ្នឹង ឃើញជាក់ស្តែងហ្នងព្រោះខ្ញុំទៅធ្វើការហ្នឹង លើកទំនប់ហ្នឹងហើយអាហ្នឹងអ្នកទោស យកចេញពីគុកគេឲ្យរែកដីហ្នង គុកគេហ្នឹងដាក់ជិតហ្នឹងដែរ ខ្ញុំទៅមើលឃើញគុកគេហ្នឹងដាក់ជិតហ្នឹងដែរ ហើយគេឲ្យជីកដីហ្នឹងក្នុង១ថ្ងៃឲ្យបាន៣-៤គីប ហើយទំនប់គេខ្ពស់ណាស់ គ្នាអត់បាយហើយវ៉ៃទៀត ហើយទ័ពគេនៅហ្នឹងហ្នងយោធាឈ្លបគេហ្នឹង ឈ្លបគេឈ្មោះអីទេប្រធាននៅហ្នឹង ប្អូនខ្ញុំនៅហ្នឹង តែប្អូនខ្ញុំវាអត់ដែលធ្វើបាបគេទេ ខ្ញុំថាកុំធ្វើបាបគេណាអូន វានៅរស់សព្វថ្ងៃហ្នឹងវានៅអូរក្រោះ ហើយដាច់ជើងត្រឹមនេះ ។

ដានី: គាត់ធ្វើអីនៅហ្នឹង?

ណៃ: វាធ្វើស្រែចំការ ពីមុនវាជាន់មីនមុនពេលរត់ វាធ្វើម៉ូដឺរី វាខាងសិល្បះនោះ ។

ដានី: ប៉ុន្តែកាលនៅជាមួយមីងគាត់ធ្លាប់ធ្វើទ័ពស្រុកហ្នឹងដែរ?

ណៃ: ចាំ! ធ្លាប់ធ្វើទ័ពស្រុកហ្នឹងដែរ ហើយវាខាងសិល្បះ ហើយវាចេះចម្រៀងចេះអីដែរហ្នឹងចេះកូដទ្រ ចេះដេញឃីកេ ដល់ហើយវានៅខាងហ្នឹង ឈ្មោះ យន់ ហ្នឹងនៅអូរក្រោះនៅជាមួយតាហ្នឹងឈ្មោះតាអីទេ ឥលូវមិនដឹងងាប់ឬក៏រស់ទេ អញ្ចឹងបានថាអ្នកនៅភូមិភាគបច្ចឹមហ្នឹងយ៉ាប់ណាស់ ។

ដានី៖ តែមីងអត់អីទេ មីងនៅពេលហ្នឹងអត់អីទេ?

ណៃ៖ គេលុតដំណាស់ ហើយម៉ែឪយើងគេចាប់ទៅគេធ្វើបាបយើងទៀតណា៎ ប៉ុន្តែយើងកសាងល្អ យើងធ្វើល្អ គេតាមដានណាស់អូន ដូចថាឪពុកយើងគេចាប់យកទៅវៃចោល ហើយគេតាមដានកូនយើងទៀត ខ្សែអ៊ីអាអីហ្នឹងគេតាមដានល្អិតណាស់ ហើយប្រវត្តិរូបយើងគេធ្វើល្អិតណាស់ យើងដឹង ហើយមានបងម្នាក់គ្រាន់ជួយ បងហ្នឹងគឺបងប្រុសណា៎ គាត់ស្រលាញ់ខ្ញុំដូចប្អូនបង្កើតអញ្ចឹង ឈ្មោះ រឿន ប្រធានពេទ្យ គាត់ថាអូនឯងធ្វើល្អមិនអីទេ យើងធ្វើល្អនៅតែបានរស់មករហូត អ្នកណាសធ្វើអាក្រក់គង់តែងាប់ទេ គាត់ថាអញ្ចឹងណា៎ យើងនិយាយបានតែគ្នាពីនាក់ស្ងាត់ៗណា៎ ហើយខ្ញុំក៏អត់ដឹងថាគាត់ហ្នឹងនឹកអាណិតខ្ញុំដែរ បងរឿន គាត់ធ្វើប្រធានពេទ្យ អូនឯងទៅព្យាបាលប្រជាជន អាណិតប្រជាជនប្រជាជនគាត់អរណាស់ គាត់ថាអញ្ចឹង គេស្រលាញ់យើង តែគ្រាន់ថាម៉ែឪយើងគេយកទៅវៃចោល ហើយយើងធ្វើល្អនៅក្នុងអាយុជីវិតយើងថ្ងៃ ហើយខ្ញុំខំធ្វើល្អ គេលុតដំខ្ញុំគេយកខ្ញុំទៅឲ្យវែកដី ថាពេទ្យហ្នឹងចេះវែកដីអត់ ខ្ញុំក៏ទៅធ្វើជាមួយគេ ប៉ុន្តែគេមិនដាក់ទោសទេណា៎ គេគ្រាន់ថាឥលូវគាត់ធ្វើការជាមួយខ្ញុំ ខ្ញុំក៏ធ្វើការដូចគេអញ្ចឹង វែកដីវែកអីជាមួយគេ ហើយគេថាគេចង់តាមដានយើង តើយើងហ្នឹងធ្វើល្អឬអត់ យើងធ្វើការបានល្អ ដល់ពេលយើងមកព្យាបាល យើងព្យាបាលហ្នឹងមានម្នាក់មកតាមដានទៀត ខ្ញុំដឹងហើយខ្ញុំក៏អត់មាត់ដែរ ធ្វើល្អរហូត មកនៅតំបន់នៅស្រុកធ្វើបានរហូតទាល់តែ។

ដានី៖ ពួកណាដែលឲ្យមីងវែកដីហ្នឹង?

ណៃ៖ ពួកមេៗពេទ្យហ្នឹង។

ដានី៖ មេៗពេទ្យហ្នឹងឲ្យមីងវែកដី?

ណៃ៖ ចា៎! មេៗពេទ្យហ្នឹងគេថាឥលូវទៅធ្វើការ ទៅជាមួយគ្នាហ្នឹង គេទៅដូចគ្នាដែរ យើងក៏ទៅគេក៏ទៅដែរ ប៉ុនគ្រាន់តែគេថាឲ្យយើងយ៉ាងម៉េចគេតាមដាន។

ដានី៖ ពេទ្យស្រុកហ្នឹងឈ្មោះអីទៅ?

ណៃ៖ ប្រធានពេទ្យស្រុកហ្នឹងឈ្មោះអីទេ ខ្ញុំភ្លេចបាត់ហើយ ទៅចាំ បងធារី វិញនៅពេទ្យតំបន់ពេទ្យតំបន់ឈ្មោះ ធារី បងអែម ពេទ្យតំបន់ដែរ ដល់ពេលពេទ្យស្រុក បងរឿន មួយហើយបងស្រីមួយ បងរឿន ហ្នឹងប្រធានថាស្រលាញ់ខ្ញុំហ្នឹង នឹកអាណិតខ្ញុំហ្នឹងបងហ្នឹងគាត់ធ្វើប្រធានដែរ ប៉ុន្តែមួយមកទៀតឈ្មោះស៊្វីទេ គេឡើងក្រោយខ្ញុំ ខ្ញុំអត់ចាំ ភ្លេចឈ្មោះបងហ្នឹងហើយប្រធានពេទ្យស្រុកហ្នឹង ឈ្មោះស៊្វីទេ ខ្ញុំមិនសូវចាំទេ។

ដានី៖ ដល់ពេលប្រធានពេទ្យតំបន់?

ណៃៈ ប្រធានពេទ្យតំបន់ បងអែម ហើយនឹងបង ធារី ស្រីៗដូចគ្នា ។

ដានីៈ អាហ្នឹងប្រធានពេទ្យតំបន់?

ណៃៈ ចាំ! ប្រធានពេទ្យតំបន់ ដែលថាពេទ្យតំបន់នៅបឹងព្រាវ ដែលខ្ញុំប្រាប់ពូមេញហ្នឹង ។

ដានីៈ តំបន់នៅបឹងព្រាវ?

ណៃៈ ហ្នឹងហើយ ពេទ្យតំបន់នៅទល់គ្នាមុខកាត់ដេរយើងពីសម័យ៣ឆ្នាំ ។

ដានីៈ អញ្ចឹងមីងនៅធ្វើពេទ្យហ្នឹងរហូតដល់៧៩?

ណៃៈ ចាំ! ធ្វើដល់៧៩រហូតបានរត់ ខ្ញុំចេញពីកន្លែងពេទ្យហ្នឹងមកនៅជាមួយប្រជាជនកន្លែងតំបន់ នៅជាមួយប្រជាជនហ្នឹងបានយើងរត់ហ្នឹង ។

ដានីៈ អញ្ចឹងកាលមីងបែក៧៩ហ្នឹងម៉េចបានជាមីងអត់ទៅផ្ទះ?

ណៃៈ មុនដំបូងថាទៅ ចាំមើលខ្ញុំនិយាយណាំ អ៊ីខ្ញុំឈ្មោះមីង ឡៃៗ ហ្នឹង ខ្ញុំដឹកឡានឥវ៉ាន់ អញ្ចឹងប៉ុន្មានឡាន ដឹកឥវ៉ាន់ ដល់សម្ភារៈឥវ៉ាន់ហ្នឹងបើកឡានទាល់តែបុកភ្នំណាំ បុកភ្នំ អញ្ចឹងមីងខ្ញុំហ្នឹងក៏បបួលថា យើងទៅរកម៉ែយើង ដល់ពេលគ្រាន់តែថាបកទៅរកម៉ែយើង គេវ៉ៃនៅមុខនេះ គេវ៉ៃហើយគេរត់ពីនោះមក មកដល់ហើយពួកហ្នឹងគេសួរថា មិត្តនារីទៅណា ខ្ញុំថាខ្ញុំទៅរកម៉ែខ្ញុំនៅសម្ពូតគោបឹង ។

ដានីៈ សម្ពូតគោបឹងនៅណាទៅ?

ណៃៈ សម្ពូតគោបឹងទៅខាងនោះទៀត ទៅខាងព្រៃភ្នំ ទៅខាងគោងឆាទៀត ហើយទ័ពព្យាងអីទៀតណាំ ខ្ញុំថាទៅហ្នឹង ដល់ពេលទៅហ្នឹងគេថាគេកំពុងតែវ៉ៃគ្នាមិត្តឯងទៅម៉េច បើខ្ញុំរត់មកពីហ្នឹងចង់ងាប់ហើយ យួនដេញ គេថាអញ្ចឹងណាំ ហើយខ្ញុំក៏អត់ទៅវិញ ដល់ពេលអត់ទៅវិញបកមកភ្នំវិញ ដល់ពេលបកមកភ្នំវិញបានរត់រហូតមកទល់សព្វថ្ងៃធ្លាក់ដល់ដីថៃហ្នឹង អាហ្នឹងវាអញ្ចឹង កុំអីខ្ញុំទៅ២នាក់មីងខ្ញុំ ប៉ុន្តែដល់ពេលទៅជំរុំ រត់មកដល់អញ្ចឹងហើយខ្ញុំពិបាកណាស់ ។

ដានីៈ មីងរបស់មីងឈ្មោះអី?

ណៃៈ មីងខ្ញុំឈ្មោះ ឡៃ ។

ដានីៈ ឈ្មោះ ឡៃ?

ណៃៈ ចាំ!

ដានីៈ ម៉េចបានជាគាត់រត់មកជាមួយមីង?

ណៃៈ មីងខ្ញុំហ្នឹង?

ដានីៈ បាទ!

ណៃៈ មីងខ្ញុំគាត់នៅពេទ្យដែរ ។

ដានីៈ នៅពេទ្យជាមួយគ្នាហ្នឹង?

ណៃៈ ចា៎! នៅពេទ្យជាមួយគ្នាហ្នឹងដែរ ។

ដានីៈ គាត់អាយុច្រើនជាងមីង?

ណៃៈ ស្រករគ្នា តែគាត់ត្រូវមីង គេសាច់ខ្ពស់យើងហៅគេមីង តែអាយុដំណាលគ្នា មីងហើយនឹងក្មួយហ្នឹង ដល់ពេលរត់ពីហ្នឹងមកឡើងភ្នំមកទាំងអស់គ្នា ដល់ពេលឡើងភ្នំមកទាំងអស់គ្នាមក ក៏ធ្លាក់មកដល់ដីថៃ មកដល់ដីថៃក៏នៅជាប់គ្នា ដល់ពេលយើង៧៩នេះខ្ញុំចូលទៅដល់ជំរុំម៉ៃរ៉ូត គេរើសទៅស្រុកក្រៅ គេសម្ភាសន៍ខ្ញុំ ខ្ញុំអត់ទៅបើខ្ញុំទៅឆ្ងាយដល់អាមេរិចហើយតែខ្ញុំអត់ទៅ ។

ដានីៈ ម៉េចបានអត់ទៅ?

ណៃៈ មីងខ្ញុំទៅទាំងអស់ មីងខ្ញុំទៅទាំងអស់ អត់តែខ្ញុំទេ ។

ដានីៈ ហេតុអីបានជាមីងអត់ទៅ?

ណៃៈ ខ្ញុំអត់ទៅ សម្ភាសន៍ជាប់ គេអ្នកស្រលាញ់ខ្ញុំហ្នឹងយកទៅប្រទេសបារាំងក៏ខ្ញុំអត់ទៅដែរ ឪពុកគាត់នៅបាត់ដំបង ហើយគាត់ធ្វើការដូចអូនឯងអញ្ចឹង គាត់ធ្វើការនៅស្រុកបារាំង ហើយគាត់យករូបថតមកឲ្យខ្ញុំមើលណា កាលហ្នឹងខ្ញុំនៅលីវ អាយុខ្ញុំអាយុប៉ុន្មានទេ ប្រហែលជាអាយុ១៥-១៦ហ្នឹង ដូចជា២០ហើយ ដល់ហើយនៅជំរុំហ្នឹងគាត់យកក៏ខ្ញុំអត់ទៅដែរ ខ្ញុំថាម៉ែឪខ្ញុំអត់នៅហ្នឹងខ្ញុំអត់ទៅទេប្រទេសគេ ខ្ញុំនិយាយអញ្ចឹងហ្មង ដល់ហើយមីងខ្ញុំគាត់ទៅ ហើយខ្ញុំទៅជួបគាត់នៅភ្នំពេញកាលលើកមុនហ្នឹងគាត់ឲ្យខ្ញុំទៅជួប ខ្ញុំទៅលេងផ្ទះហ្នឹង ថាឲ្យទៅជួបមីងហ្នឹង ដល់ហើយគាត់មីអូនម៉េចក៏អញរកឯងមិនឃើញទៅស្រុកក្រៅ ហើយឯងឡើងឡានម៉េចមិនព្រមឡើងឡាន គាត់ថាអញ្ចឹងណា៎ ដល់ខ្ញុំអត់ទៅ ខ្ញុំថាខ្ញុំអត់ទៅទេ គាត់ថាអញខំរកឯង ដល់ហើយគាត់មានកូនមានចៅទៅអាមេរិចហ្នឹង មីងខ្ញុំហើយនឹងពូខ្ញុំនៅអាមេរិចទាំងអស់ អត់តែខ្ញុំទេ ។

ដានីៈ គាត់មកលេងស្រុកដែរ?

ណៃៈ គាត់មក មកហើយខ្ញុំនៅនេះ ហើយមីងខ្ញុំផ្តាំមកចាំខ្ញុំចំនួន១ខែ តែគេអត់ប្រាប់ខ្ញុំ អ្នកស្រុកភូមិហ្នឹងគេទៅលេងផ្ទះទល់តែមីងខ្ញុំមក ដល់ពេលមីងខ្ញុំមកគេប្រាប់ថាបងឯងទៅលេងផ្ទះ មីងខ្ញុំគាត់ហៅខ្ញុំហៅមីស្គម កាលហ្នឹងខ្ញុំស្គមណាស់ គាត់ថាឲ្យមីស្គមមកលេងខ្ញុំផង ខ្ញុំចាំវា១ខែ ថាមីងមកពីក្រៅឈ្មោះមីង ឡៃ ដល់ហើយគេអត់ប្រាប់ ។

ដានីៈ គេអត់ប្រាប់ទេ?

ណៃៈ គេអត់ប្រាប់ នៅឆ្ងាយដែរ នៅម្តុំពីរនោះ គេអត់ប្រាប់អញ្ចឹងមីងខ្ញុំក៏អត់ទៅ ហើយខ្ញុំទៅជួបមុនដំបូងមីងខ្ញុំឲ្យ បែបគេខ្លាចយើងមានទៅដឹងបានគេមិនប្រាប់យើង ហើយខ្ញុំក៏អត់ថាអីដែរ គេអត់ប្រាប់ខ្ញុំថាចាំថ្ងៃក្រោយទៀតទៅ ចាំខ្ញុំទៅជួបមីងខ្ញុំក៏បានដែរ ខ្ញុំថាមីងខ្ញុំឲ្យលុយកាក់អីក៏ឲ្យទៅ បើគាត់មិនឲ្យក៏មិនដឹងធ្វើម៉េចដែរព្រោះយើងអត់ទៅ ហើយមីងខ្ញុំក៏ម៉ែឪស្លាប់អស់ហើយ កាលហ្នឹងគាត់ទៅអាមេរិចទាំងអស់ អត់តែខ្ញុំទេ ខ្ញុំអត់ទៅហ្នឹងសម្ភាសន៍ជាប់ទាំងអស់ ខ្ញុំធ្វើការនៅកន្លែងហ្នឹង ទៅដល់នោះយើងធ្វើការណា៎ យើងពេទ្យយើងចេះហើយណា៎ យើងចង់ចូលពេទ្យធ្វើការក៏បាន ខ្លាចតែយើងអត់ចេះអក្សរ ប៉ុន្តែគេសួរចេះឆ្លើយក៏ចេះ ខ្ញុំថាអញ្ចឹងៗខ្ញុំចេះហើយ ខ្ញុំថាខ្ញុំធ្វើបានគ្រាន់តែខ្ញុំអត់ធ្វើ ។

ដានីៈ ចុះមីងនៅជំរុំហើយចេញមកនៅដីខ្មែរវិញ?

ណៃៈ នៅជំរុំហ្នឹងគេរើស គេរើសកម្លាំងមក ដែលថាយើងស្ម័គ្រចិត្តណា៎ ដល់ពេលយើងស្ម័គ្រចិត្តអញ្ចឹង ថាយើងមកនេះបម្រុងមករកម៉ែ ថាយើងចេញពីជំរុំមកយើងអត់នៅទេប្រទេសគេ យើងចេញមកយើងអត់ទៅក្រៅ យើងចេញមកថាមករកម្តាយ ដល់ពេលមករកម្តាយអត់បានជួបទៀត ហើយប្អូនក៏អត់បានជួបទៀត រហូតដល់ម្តាយស្លាប់បានខ្ញុំនៅនេះរហូតទៅ ទៅជួបម្តាយខ្ញុំមានបានជួបណា៎ ប្អូនៗថាម្តាយខ្ញុំស្លាប់ហើយ ខ្ញុំអត់ទៅដោយសារ ហើយគេនិយាយទៀតថា ចែបើសិនជាទៅប្រទេសក្រៅ ចែឯងបានជួបម្តាយហើយ បានលុយបានកាក់ព្យាបាលម្តាយ គេថាអញ្ចឹង ដល់ហើយខ្ញុំថាមិនដឹងថាម៉េចទេ អាហ្នឹងវាអញ្ចឹងហើយ បើចិត្តយើងអត់ទៅសោះ គេអ្នកចង់បានគេអ្នកចង់ទៅគេសុំពីខ្ញុំ ខ្ញុំថាយកចុះ ដែលឯងចង់ទៅអាមេរិច ជាពិសេសចិន គេថាបងឯងគេឲ្យទៅម៉េចក៏មិនទៅ មានខ្សែរយៈទៅហើយម៉េចក៏មិនទៅ ខ្ញុំមកនៅនេះយូហើយខ្ញុំចង់ទៅអាមេរិចណាស់មិនបានទៅសោះគេថាអញ្ចឹង ខ្ញុំថាឯងចង់ទៅក៏ទៅឯងយកទៅ ទៅៗខ្ញុំអត់ទៅទេ អ៎!គេទៅច្រើនណាស់ ប្រទេសអាមេរិចហ្នឹងគេហៅហ្នឹង អាហ្នឹងបងប្អូនសុទ្ធតែទៅហ្នឹងទាំងអស់ ។

ដានីៈ ចុះដល់ពេលមីងមក?

ណៃៈ ខ្ញុំមកនេះវិញជួបតែប្អូនទេ ជួបតែប្អូនជីដូនមួយទៀត អត់មានជួបអ្នកណាទាំងអស់ ។

ដានីៈ មីងមកចូលដល់ដីខ្មែរវិញបានជួប?

ណៃៈ ហ្នឹងហើយដល់ពេលមកចូលដល់ដីខ្មែរហ្នឹង៨០-៨១បានខ្ញុំរៀបគ្រួសារជាមួយខ្ញុំហ្នឹងរៀបគ្រួសារហ្នឹងខ្ញុំរៀបនៅថ្មដារ មេការឲ្យ ព្រោះខ្ញុំនៅជាមួយមេជាប់រហូត ។

ដានីៈ មីងនៅជាមួយពីណាខ្លះ?

ណៃៈ	កាលនៅដឹកជញ្ជូននៅជាមួយ ឃីម នៅកងពល ។

ដានីៈ	នៅកងពលណា?

ណៃៈ	កងពលនារី គាត់នៅអូរដើមចេក ។

ដានីៈ	អូរដើមចេក?

ណៃៈ	ចាំ!

ដានីៈ	អូរដើមចេកនៅណាទៅ?

ណៃៈ	នៅយើងសម្ពួតនេះ ។

ដានីៈ	នៅក្នុងស្រុកសម្ពួត?

ណៃៈ	ចាំ!

ដានីៈ	ឈ្មោះ ឃីម ហ្នឹងស្រីមែន?

ណៃៈ	ចាំ! ស្រី គាត់រៀបគ្រួសារឲ្យ ដល់ពេលខ្ញុំរៀបមករៀបនៅកន្លែង តាសេង តាសេង កងពលណាំ តែគាត់ស្លាប់បាត់ហើយ ។

ដានីៈ	តាសេង កងពលធំ?

ណៃៈ	ចាំ! ប៉ុន្តែឥលូវគាត់ស្លាប់ហើយ ។

ដានីៈ	គាត់ស្លាប់ពីអន្តាល់?

ណៃៈ	គាត់ខ្យល់ ហើយដាក់សេរ៉ូម ដល់ហើយផាប់ហ្នឹង គាត់មេ គាត់កងពល ម៉ោងថ្មើរហ្នឹង ថ្ងៃថ្មើហ្នឹង រៀបពេលថ្ងៃល្ងាច រៀបតែមួយគ្រួសារទេ តែមួយគូរទេ បើគេសម័យ៣ឆ្នាំ គេរៀបច្រើនៗគូរណាស់ គេរៀបម្តង១០គូរ ។

ដានីៈ	ចុះមីងបានទៅលេងផ្ទះនៅឆ្នាំណា?

ណៃៈ	ខ្ញុំបានទៅលេងផ្ទះឆ្នាំ២០០១ អាហ្នឹងម្តាយឪពុកស្លាប់អស់ហើយ បងប្អូនស្លាប់អស់ហើយ ហើយគេថាខ្ញុំស្លាប់គ្រប់គ្នា ព្រោះវាយូ មិនដែល តាំងពីចេញពីបដិវត្តន៍មិនដែលទៅផ្ទះសោះ ។

ដានីៈ	អត់ដែលទៅសោះ?

ណៃៈ	អត់ដែលទៅសោះ ដល់ហើយទៅគេថាមិនដែលឃើញមុខឯង ។

ដានីៈ	ចុះមីងមានដែលនៅជាមួយតាៗដែរ ដូចជាតា នួន ជា តាប៉ុល ពត អីហ្នឹង?

ណៃៈ	នៅក្បែរៗអត់នៅជិតទេ យើងនៅកងការពារដូចថា នៅដំណាក់ទី២ទី៣អញ្ចឹង ។

ដានីៈ	កាលហ្នឹងនៅណា?

ណៃៈ	កាលហ្នឹងនៅព្រំដែន ម៉ាដូវព្រំដែន៨២-៨៣ហ្នឹង ។

ដានីៈ ម៉ុំណាហ្នឹង?

ណៃៈ ម៉ុំចម្ការស្រូវ "ច១" ។

ដានីៈ នៅម៉ុំចម្ការស្រូវនៅណា?

ណៃៈ យើងទៅខាងនេះថ្មដារ ។

ដានីៈ ចុះតាៗគាត់នៅកន្លែងណា?

ណៃៈ គាត់នៅដីថៃ តែបងៗខ្ញុំគាត់នៅកន្លែងប៉ុស្តិ៍ ។

ដានីៈ កាលពី៨១គាត់នៅដីថៃ គេហៅអីគេហ្នឹង កន្លែងគេហៅឈ្មោះអីទេ?

ណៃៈ អត់ស្គាល់ទេកន្លែងភូមិហ្នឹង ។

ដានីៈ ដល់ពេល៨៣បានគាត់ឡើងមកវិញ?

ណៃៈ ដល់ពេល៨៥បានគាត់ចុះមកនៅក្រោ យើងនៅក្បែៗហ្នឹងកងការពារមួយដំណាក់ៗ ទី១ ទី២ ទី៣ ហើយយើងទី៤ ។

ដានីៈ ដល់ក្រោយមកគាត់ទៅនៅណាទៀត ចេញពីដីថៃមកនៅដីខ្មែរ?

ណៃៈ ចេញមកគាត់មកនេះមួយសារ ។

ដានីៈ តាទួន ជា គាត់នៅ?

ណៃៈ គាត់នៅសម្លូត ។

ដានីៈ ហើយតាប៉ុល ពត?

ណៃៈ តាប៉ុល ពត គាត់នៅដីថៃ ។

ដានីៈ ហើយតាអៀង សារី គាត់នៅប៉ៃលិន?

ណៃៈ ចាំ! បើកាលខ្ញុំទៅជួបនៅស្អីគេកន្លែងពេទ្យហ្នឹង ដូចជានៅកន្លែងប៉ុស្តិ៍វិទ្យុ ។

ដានីៈ ប៉ុស្តិ៍វិទ្យុនៅកន្លែងណា?

ណៃៈ នៅចាន់រ៉ាំរី ។

ដានីៈ ចាន់រ៉ាំរីក្នុងដីថៃ?

ណៃៈ ចាំ! ខ្ញុំថាបើរបបពេទ្យហ្នឹងទៅចាន់រ៉ាំរីហ្នឹង តាឲ្យទៅ ដល់ហើយថ្នាក់ទាក់ទងទៅយកខ្ញុំទៅក៏មកវិញមកអត់បានទៅបើកសម្ភារៈពេទ្យហ្នឹងណាំ ដល់ហើយខ្ញុំថាមិនបាច់ទេអញ្ចឹង ខ្ញុំថាខ្ញុំមានលុយទិញខ្លួនឯង តែឥលូវខ្ញុំថាខ្ញុំឈប់ធ្វើហើយតា ខ្ញុំឈប់ធ្វើពេទ្យហើយ ។

ដានីៈ តាជួន ជឿន?

ណៃៈ ចាំ! គាត់ស្លាប់ហើយ ។

ដានីៈ គាត់ស្លាប់ហើយ?

ណៃៈ ចា៎! ស្លាប់ហើយ ។

ដានីៈ ស្លាប់ពីអន្លាល់?

ណៃៈ មិនដឹងស្លាប់ពីអន្លាល់ទេ នឿន ប្រាប់ខ្ញុំថាស្លាប់បាត់ហើយ ក្មួយតាបង្កើត ។

ដានីៈ ឈ្មោះអីគេ?

ណៃៈ ឈ្មោះ នឿន ក្មួយយាយ ស៊ិន ។

ដានីៈ គាត់នៅណាឥលូវ?

ណៃៈ គាត់ទៅប៉ៃលិនវិញហើយ ។

ដានីៈ គាត់មកនៅហ្នឹង?

ណៃៈ មកនៅហ្នឹង គេយកប្ដីចិន វាពេទ្យ ។

ដានីៈ ប្ដីចិនម៉េច?

ណៃៈ ប្ដីវាហ្នឹងចិននៅស្រុកខ្មែរយើងណា៎ ហើយ នឿន ហ្នឹងក៏វាចេះចិនដែរ ពីសម័យ៣ឆ្នាំវាទៅស្រុកចិន រៀនចិនវាចេះចិនអញ្ចឹងទៅ បើចិនមកស្រុកខ្មែរយើងវាយកប្ដីចិនហ្នឹង យកប្ដីចិនតាពេទ្យហ្នឹងគាត់ធ្លាប់នៅជាមួយខ្មែរក្រហម អញ្ចឹង នឿន ហ្នឹងយកគាត់នៅ១០ឆ្នាំហើយយកប្ដីចិនហ្នឹង ។

ដានីៈ ឥលូវនៅប៉ៃលិន?

ណៃៈ នៅប៉ៃលិន ។

ដានីៈ ប្ដីគាត់នៅប៉ៃលិនដែរ? ៖

ណៃៈ ទៅមកៗ ។

ដានីៈ ទៅស្រុកចិនទៅមកៗ?

ណៃៈ ចា៎! ។

ដានីៈ ចុះមីងអត់បានជួបមីងឈ្មោះ ឡៃ ហ្នឹងទេ?

ណៃៈ អត់ដែលបានជួបទេ បានតែតាមទូរស័ព្ទ ។

ដានីៈ បានជួបតាមទូរស័ព្ទដែរ?

ណៃៈ ចា៎! ខ្ញុំទៅយកលុយនៅភ្នំពេញហ្នឹង មីងគាត់ផ្ញើរមកហ្នឹងខ្ញុំទៅយកជួបបានម្ដងហ្នឹង ។

ដានីៈ ជួបគាត់ឬក៏ជួប?

ណៃៈ ជួបគាត់ហ្នឹង ។

ដានីៈ ជួបតាមទូរស័ព្ទ?

ណៃៈ និយាយតាមអ៊ីនធើណេតហ្នឹង ។

ដានី៖ ពីអន្កាល់មីង?

ណៃ៖ កាលខ្ញុំទៅលេងផ្ទះហ្នឹង ។

ដានី៖ កាល២០០១ហ្នឹង?

ណៃ៖ កាល២០០២ ជួបបានម្ដងហ្នឹង ដល់ក្រោយមកគាត់មកលេងស្រុកគេផ្ដាំឲ្យទៅ គាត់ចាំខ្ញុំមួយខែគេអត់ប្រាប់ខ្ញុំ ហើយខ្ញុំក៏អត់ដឹង អត់ដឹងថាអ្នកណាមក ដល់ពេលអញ្ចឹងគេអត់ប្រាប់ឲ្យទៅជួប គាត់ចាំឡើងមួយខែ ដល់ពេលក្រោយមកគាត់ប្រាប់ថា មីងខំចាំមួយខែហើយឥលូវមានបានលេខទូរស័ព្ទណា ខ្ញុំថាចាំក្រោយនេះទៅឲ្យគាត់មកលេង ។

ដានី៖ គាត់នៅទឹកឃើញមីងដែរ?

ណៃ៖ នៅទឹកឃើញ ព្រោះកាលគាត់ឈឺខ្ញុំព្យាបាល គាត់កុំតែបានខ្ញុំកុំអីក៏ងាប់ដែរ ។

ដានី៖ គាត់ផ្ញើរលុយឲ្យដែរ?

ណៃ៖ ផ្ញើរឲ្យ ពេលខ្ញុំទៅគាត់ឲ្យ បើសិនជាអត់ខ្ញុំក៏ងាប់ដែរមីង ព្រោះខ្ញុំព្យាបាលគាត់ ។

ដានី៖ ធ្លាប់ព្យាបាលគាត់ដែរ?

ណៃ៖ ចាំ! គាត់ធ្វើពេទ្យដែរ តែគាត់ឈឺ ឈឺយើងកំពុង៧៩ហ្នឹង អញ្ចឹងបានគាត់អត់អស់អាល័យហ្នឹង ពេលមកហ្នឹងគាត់ផ្ដាំថាឲ្យមីស្គមទៅជួបយើង ឲ្យវាមកលេងយើង យើងមកពីប្រទេសក្រៅថាមកចង់ជួបប្អូន ហើយកូនគាត់អត់មានចេះខ្មែរមួយម៉ាត់ គាត់ថានិយាយជាមួយ ។

ដានី៖ ហើយចុះប្ដីគាត់ខ្មែរមែន?

ណៃ៖ ខ្មែរទេ យកពីហ្នឹងទៅ យកពីជំរុំហ្នឹងទៅ គាត់យកគ្នាហ្នឹងទៅស្រុកក្រៅហ្នឹងទម្ងន់បាន២ខែហើយ គាត់ទៅហ្នឹងហើយខ្ញុំរត់ពួនគាត់ ថាគាត់ទៅឡើងឡានទៅហ្នឹងខ្ញុំរត់ពួនគាត់ ។

ដានី៖ គាត់នៅរដ្ឋណា?

ណៃ៖ គាត់នៅរដ្ឋកាលីហ្វញ៉ា គាត់ថាអញ្ចឹងឯង គាត់នៅហ្នឹង ប៉ុន្តែខ្ញុំសួររកពូខ្ញុំគាត់ថាអត់មានអ្នកណាសោះ គាត់នៅតែម្នាក់ឯង ខ្ញុំថាមីងសួរពូផង ទៅអាមេរិចហ្នឹង ពូខ្ញុំបង្កើតប្អូនឪពុកខ្ញុំបង្កើតកូនពៅ គាត់ថាអត់ឃើញសោះ ។

ដានី៖ ហើយដែលមកលេងផ្ទះទេពូរបស់មីង?

ណៃ៖ ពូខ្ញុំអត់សោះ ប៉ុន្តែខ្ញុំរកគេមើលគេថាស្លាប់ហើយ តែបែបស្លាប់មែនហើយព្រោះគាត់ចាស់ហើយ ។

ដានី៖ គាត់ចាស់ហើយ?

ណៃ៖ ហ្នឹងហើយ គាត់ចាស់ហើយ គាត់រកស៊ីប្រាក់អាត្រែត មិនដឹងម៉េចរឿងរ៉ាវហ្នឹង ខ្ញុំកំសត់ណាស់ កំសត់ត្រង់ម៉ែឪខ្ញុំលុតដំ ខ្ញុំធ្វើល្អបានល្អទឹកឃើញអញ្ចឹង ហើយ៧៩នេះខ្ញុំជួយយកអាសារគេច្រើនណាស់ កូនក្មេងដែលគេហែលទឹកមិនរួចណា៎ ដូចយើងថ្នាំពេទ្យមានប៉ុន្មានយើងឲ្យគេហូបហើយ ប្រជាជនអត់បាយអញ្ចឹងយើងឲ្យគេហូប ដល់ពេលហែលទឹកកូនក្មេងប៉ុនៗកូនខ្ញុំមេញនេះ៤នាក់ ទឹកជន់ហូរខ្លាំងណាស់គេហែលអត់រួចទេ គេរត់ចោលអស់ គេទៅអស់ ហើយខ្ញុំទឹកត្រឹមក ទឹកត្រឹមកអញ្ចឹងដែលវាហៅថាមីងអើយជួយខ្ញុំផងមីងឯងយកខ្ញុំឲ្យបានទៅត្រើយម្ខាង ខ្ញុំទៅជាមួយមីងឯងដែរ ខ្ញុំបានកៅស៊ូមួយចងក្រណាត់ដាក់ឥវ៉ាន់នៅក្នុងហ្នឹងមានអង្ករស្អីៗ ហើយក៏ឲ្យក្មេងហ្នឹងវាហែលតាមពីក្រោយខ្ញុំឲ្យតោងខ្ញុំឲ្យជាប់ ដល់ពេលទឹកវិខ្លាំងពេកខ្ញុំចាប់ក្បាលហ្នឹងបោចមកជិតខ្ញុំ ហើយហែលឃើញតែក្បាលបន្តិចៗហ្នឹង ឲ្យតោងគ្នាឲ្យជាប់ណា៎ គិតទៅខ្ញុំដើរបានតែទឹកត្រឹមកកំពុងហូរហើយគេទៅអស់ ហើយមីងខ្ញុំនៅតែបន្ទោសខ្ញុំថា ឯងអាល័យតែយកគេយកអាសារគេណាស់ ខ្លួនឯងមិនគិតទេ នែក៎អញចាំឯងគេទៅចោលអស់ហើយ គាត់ចាំខ្ញុំមែន គាត់ថាក្អួយអាល័យតែយកគេ ទៅយកអាក្មេងៗហ្នឹង ទៅដល់ខ្ញុំដោះអាវដោះខោឲ្យវាម្នាក់មួយ ខ្ញុំពាក់ច្រើនជាន់ណាស់ខោអាវ ដោះអាវដៃខ្លីឲ្យវាម្នាក់មួយៗ ដល់ពេលទៅដល់ជំរុំកូនក្មេងទាំងអស់ហ្នឹងបានទៅស្រុកក្រៅអស់ទៅ ខ្ញុំជួយឲ្យវាទៅនៅកន្លែងកុមារកំព្រា នៅកុមារកំព្រាហើយបានឲ្យក្មេងហ្នឹងទៅប្រទេសក្រៅអស់ សុទ្ធតែប្រុសតូចៗវាដឹងវាទៅក្រៅអស់ហើយ គេថាបើសិនជាថ្ងៃក្រោយជួបមីងឯងមីងឯងជួយខ្ញុំ ខ្ញុំឲ្យមីងព្រោះខ្ញុំទៅប្រទេសក្រៅ សព្វថ្ងៃប្រហែលជាវារកខ្ញុំមិនឃើញតាមមើល មិនដឹងយ៉ាងម៉េចប្រហែលជាអត់ដឹងខ្សែរយៈ ។

ដានី៖ គេស្គាល់ឈ្មោះមីងដែរ?

ណៃ៖ គេស្គាល់ ។

ដានី៖ ហើយគេនោះមានឈ្មោះអីដែរ?

ណៃ៖ គេនោះឈ្មោះ ហេង ឈ្មោះ អាត ។

ដានី៖ សុទ្ធតែប្រុសៗ?

ណៃ៖ សុទ្ធតែក្មេងប្រុសៗទាំង៤នាក់ហ្នឹង ។

ដានី៖ ឈ្មោះ ហេង ហើយឈ្មោះ អាត?

ណៃ៖ ចា៎! គេទៅប្រទេសក្រៅអស់ហើយ ។

ដានី៖ ស្គាល់តែប៉ុណ្ណឹងទេ អត់មានស្គាល់អ្នកផ្សេងទៀតទេ?

ណៃៈ ២នាក់ទៀតខ្ញុំភ្លេចឈ្មោះបាត់ហើយ វាតូចៗដូចគ្នា មានបានប៉ុណ្ណេះណា៎ មានបានប៉ុនកូនខ្ញុំណា៎ ធំជាងអាមួយអង្គុយទីនេះបន្តិចហ្នឹង អញ្ចឹងបានខ្ញុំថាខ្ញុំជួយយកអាសារគេព្រះជួយហើយ ខ្ញុំថាអញ្ចឹង ប៉ុន្តែវេទនាណាស់គិតទៅ មួយប្រាវអញ្ចឹងទៅងាប់អស់អាលីងនៅតែខ្ញុំមួយ ឆ្លងថ្មុកឈាមអូនកាលរត់ហ្នឹង បាញ់អាបេមកបុកមួយមាំងអញ្ចឹងទៅសាក់កាដូរពេទ្យខ្វាយ ខ្ញុំស្រវ៉ាបានបាយតែមួយម៉ាត់ទេទៅទៀត ងាប់អស់អាលីង នៅតែខ្ញុំទេរត់ទៅហ្នឹង រត់ទៅជួបគេជួបឯងហើយទៅដល់ខាងមុខបានជួបមេហ្នឹងបានដឹងថាយើងហ្នឹងបានជាប់ វៃពីរសារកំពុងរត់ហ្នឹង គេថាចាប់រស់ៗ ហើយខ្ញុំចោលអស់ហើយស្អីក៏អត់មានដែរ ។

ដានី៖ មីងទៅលេងផ្ទះបានប៉ុន្មានដងដែរ?

ណៃៈ បានតែមួយដងគត់ ខ្ញុំអត់មានបច្ច័យ ពីឆ្នាំទៅមិញថាទៅ ដល់ហើយធ្វើអីអត់បាននឹកឃើញលុយតិចពេកអត់ទៅ មុនទៅតែ២នាក់ទេ ដល់លើកនេះថាទៅៗឲ្យបាន គ្រួសារខ្ញុំក៏អត់បានទៅ ទៅតែខ្ញុំហើយនឹងកូន ដល់អញ្ចឹងថាលើកនេះបើសិនបានលុយថាទៅឲ្យបានលុយច្រើនធ្វើបុណ្យធ្វើអីផង ដល់អញ្ចឹងរហូតដល់សព្វថ្ងៃហ្នឹងបាននិយាយទូរស័ព្ទទៅមកជាមួយប្អូន ។

ដានី៖ និយាយជាទូរស័ព្ទជាមួយប្អូន?

ណៃៈ ដូចថានឹកប្អូនអញ្ចឹងនិយាយជាមួយប្អូន ប្រុសណា៎ និយាយទៅប្អូនវាថាថៃអើយខ្ញុំកំពុងចាប់ក្តាម ប្អូនខ្ញុំរកស៊ីចាប់ត្រីទាំងអស់នៅសមុទ្រទាំង៣-៤នាក់ ហើយប្រុសនៅសល់តែ២នាក់ទេ គេវៃចោលមួយហើយ ប្រុស៣នាក់ ហើយស្រីៗនៅទាំងអស់ ។

ដានី៖ អញ្ចឹងមីងខ្ញុំអរគុណមីងច្រើនដែលបានសំណេះសំណាលជាមួយខ្ញុំ ។

ណៃៈ ចា៎!

**«ចប់»**